**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សារណាបញ្ចប់ការសិក្សា**

# ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយលើលទ្ធផលសិក្សារបស់និស្សិត

ចុះស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

រៀបរៀងដោយៈ

និស្សិតឈ្មោះ **ស៊ុន មល្លីកា**

**ឃី ឌីណាល់**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ខ៉ាន់ ស៊ុនដេត**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទឈ្មោះ ឃី ទីណាល់ និងនាងខ្ញុំឈ្មោះ ស៊ុន មល្លិកា សូមគោរពសំដែងការដឹងគុណចំពោះអ្នកមានគុណទាំងទ្វេ រួមមានលោកឪពុក និងអ្នកម្ដាយដែលលោកទាំងពីរបានចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់កម្លាំងចិត្ត និងដំបូន្មានល្អៗដើម្បីឲ្យកូនបានក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម និងជាពិសេសបានខិតខំតស៊ូ និងលះបង់គ្រប់បែបយ៉ាងដើម្បីឲ្យកូនទទួលបានការអប់រំខ្ពង់ខ្ពស់ដូចសព្វថ្ងៃ។

លើសពីនេះទៅទៀត យើងខ្ញុំទាំងពីរនាក់សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្ដមសាកលវិទ្យាធិការ គណៈគ្រប់គ្រង និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទ-នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានខិតខំបង្ហាត់បង្រៀនយើងខ្ញុំទាំងពីរនាក់ ក៏ដូចជានិស្សិតដ៏ទៃទៀតយ៉ាងយកចិត្តទុកដាក់ និងចែករំលែកចំណេះដឹងដ៏ច្រើនដល់និស្សិតពីមួយជំនាន់ទៅមួយជំនាន់ដោយពុំខ្លាចនឿយហត់។ សារជាថ្មីម្ដងទៀត យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជាពិសេសចំពោះលោកសាស្ត្រាចារ្យ ***បណ្ឌិត ង៉ាន់ ស៊ុនដេត*** ដែលលោកគ្រូបានចំណាយពេលវេលាដ៏មានតម្លៃបំផុត ក្នុងការដឹកនាំក្រុមយើងខ្ញុំសរសេរសារណាបញ្ចប់ការសិក្សារួមជាមួយការផ្ដល់ដំបូន្មានល្អៗ ការលើកទឹកចិត្ត ការពន្យល់ណែនាំ ការបង្ហាញផ្លូវ និងការជួយកែតម្រូវរាល់ចំណុចខ្វះខាត ចាប់តាំងពីពេលចាប់ផ្ដើមសរសេររហូតដល់សារណារបស់ក្រុមយើងខ្ញុំត្រូវបានបញ្ចប់ដោយជោគជ័យ។

ម្យ៉ាងវិញទៀត យើងខ្ញុំទាំងពីរនាក់ក៏សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តរួមថ្នាក់ មិត្តភក្ដិ និងបងប្អូននិស្សិតដ៏ទៃទៀតទាំងអស់ដែលបានចែករំលែកចំណេះដឹង រិះគន់ដើម្បីស្ថាបនា និងបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមឆ្លើយសំណួរស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ។

ជាចុងក្រោយ យើងខ្ញុំសូមគោរពជូនពរអ្នកទាំងអស់គ្នាឲ្យរកទទួលទានមានបាន និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីអាក់ខានឡើយ។

# អារម្ភកថា

បន្ទាប់ពីការធ្លាក់ចុះនៃសម័យអង្គរនៅសតវត្សទី១៥ គ្រឹះស្ថានថ្នាក់ឧត្តមសិក្សារបស់ប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញ និងបិទទ្វារដោយសារតែសង្គ្រាម និងការឈ្លានពានពីប្រទេសជិតខាងរួមមានថៃ និងវៀតណាម។ ក្នុងកំឡុងពេលដ៏លំបាកនោះ វត្តអារាមបានក្លាយទៅជាកន្លែងអប់រំយ៉ាងសំខាន់សម្រាប់អ្នកប្រាជ្ញ និងបញ្ញវន្តខ្មែរ។ ដើម្បីបញ្ឈប់មហិច្ឆតាឈ្លានពានរបស់ប្រទេសទាំងពីរ ព្រះបាទអង្គដួង (១៧៩៧-១៨៦០) បានអញ្ជើញបារាំងមកធ្វើជាអាណាព្យាបាលនៅឆ្នាំ ១៨៦៣ តែគួរឲ្យសោកស្ដាយបំផុត ប្រទេសកម្ពុជាក៏បានធ្លាក់ចូលក្នុងសង្គ្រាមត្រជាក់សាជាថ្មីម្ដងទៀតនៅឆ្នាំ ១៩៧០ ដែលពេលនោះ ការអប់រំថ្នាក់ឧត្តមសិក្សាត្រូវបានបំផ្លាញស្ទើរទាំងស្រុង។ សោកនាដកម្មដ៏ធំបំផុតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ ១៩៧០-១៩៧៩ បញ្ញវន្តខ្មែរ អ្នកប្រាជ្ញ និងអ្នកចេះដឹងជាច្រើនត្រូវបានបាត់បង់នៅក្នុងរបបប្រល័យពូជសាសន៍នោះ។ ក្រោយពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់នៅក្នុងឆ្នាំ ១៩៩៨ កម្ពុជាបានខិតខំយ៉ាងខ្លាំងក្នុងការអភិវឌ្ឍ និងធ្វើកំណែទម្រង់ប្រព័ន្ធអប់រំថ្នាក់ឧត្តមសិក្សារហូតមកដល់បច្ចុប្បន្ន។

ដោយសារតែកត្តាស្ថេរភាពនយោបាយ និងការរីកចំរើនឆាប់រហ័សនៃបច្ចេកវិទ្យាទំនើបៗ វិស័យអប់រំក្នុងប្រទេសកម្ពុជា កាន់តែដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការកសាងមូលធនមនុស្សសម្រាប់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងការសម្របខ្លួនទៅនឹងការប្រែប្រួលរបស់ពិភពលោក ។ ម្យ៉ាងវិញទៀត ដោយសារតែការសាយភាយជាលក្ខណៈសកលនៃសេរីភាវូបនីយកម្ម វាបានបង្កើតនូវបរិយាកាសមួយដែលមានការប្រកួតប្រជែងខ្លាំង ដែលទាមទារឲ្យមនុស្សម្នាក់ៗជាពិសេសយុវជនត្រូវប្រឹងប្រែងបង្កើនសមត្ថភាព ជំនាញបច្ចេកទេស និងចំណេះដឹងឲ្យបានច្រើនតាមតែអាចធ្វើទៅបាន។ ហេតុដូច្នេះហើយ និស្សិតកម្ពុជាបច្ចុប្បន្នមានការចាប់អារម្មណ៍លើការសិក្សាយ៉ាងខ្លាំង ដោយមានអ្នកខ្លះរៀនបណ្តើរ រកកំរៃបណ្តើរ រីឯអ្នកខ្លះទៀត រៀនពីរជំនាញក្នុងពេលតែមួយក៏មាន។ ការរៀនពីរជំនាញក្នុងពេលតែមួយនេះកំពុងតែមានភាពពេញនិយមយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ អាស្រ័យហេតុនេះហើយ ទើបយើងទាំងពីរនាក់បានជ្រើសរើសយកប្រធានបទ ***"ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយលើលទ្ធផលនៃការសិក្សារបស់និស្សិត"*** ដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍។ យើងខ្ញុំមានគោលបំណងធំៗចំនួនពីរ៖ ទី១ ដើម្បីបង្ហាញនិងបកស្រាយពីមូលហេតុដែលជម្រុញឲ្យនិស្សិតសម្រេចចិត្តសិក្សាពីរជំនាញក្នុងពេលតែមួយ និងទី២ ដើម្បីបង្ហាញនិងពន្យល់ពីឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយ ទៅលើលទ្ធផលនៃការសិក្សារបស់និស្សិត។ យើងខ្ញុំសង្ឃឹម

ថា ការសិក្សាស្រាវជ្រាវមួយនេះនឹងផ្តល់ជាគំហើញ និងពត៌មានមូលដ្ឋានសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយដើម្បីធ្វើការសម្រេចចិត្តជ្រើសរើសជំនាញចូលរៀនថ្នាក់ឧត្តមសិក្សា។ លើសពីនេះស្នាដៃមួយនេះនឹងបើកផ្លូវសម្រាប់ការសិក្សាស្រាវជ្រាវក្រោយៗទៀត។

បើទោះបីជា ការសិក្សាស្រាជ្រាវនេះត្រូវបានបញ្ចប់ដោយជោគជ័យក៏ពិតមែន ប៉ុន្តែយើងខ្ញុំជឿជាក់ថា កិច្ចការមួយនេះនៅមិនទាន់មានអត្ថន័យគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវឥតខ្ចោះនៅឡើយទេ ជាពិសេសផ្នែកអក្ខរាវិរុទ្ធ។ ដូច្នេះ យើងខ្ញុំទាំងពីរនាក់រីករាយក្នុងការទទួលយក និងឲ្យតម្លៃខ្ពស់ចំពោះការចូលរួមរិះគន់ ដើម្បីស្តាបនាពីគ្រប់មជ្ឈដ្ឋានទាំងអស់ដើម្បីកែលម្អការស្រាវជ្រាវមួយនេះ ឲ្យមានសុក្រឹតភាពខ្ពស់អាចទទួលយកបាន។

## មាតិកា


បញ្ជីតារាង ....... iii

បញ្ជីក្រាហ្វិក....... iv


## សេចក្តីផ្តើម


១. លំនាំបញ្ហា និងការកំណត់បញ្ហា ....... ១

២. គោលបំណងនៃការស្រាវជ្រាវ ....... ២

៣. សំណួរស្រាវជ្រាវ....... ២

៤. សារៈសំខាន់នៃការស្រាវជ្រាវ....... ២

៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ....... ៣

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ....... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ....... ៤


## ជំពូកទី ១

## ទ្រឹស្តីដែលពាក់ព័ន្ធនឹងការសិក្សាពីរជំនាញក្នុងពេលតែមួយ


១.១. កត្តាដែលជំរុញឲ្យនិស្សិតសិក្សាពីរជំនាញក្នុងពេលតែមួយ....... ៥

១.២. ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលក្នុងពេលតែមួយលើឱកាសការងារ
និងកម្រិតប្រាក់ចំណូល ....... ៦

១.៣. ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយលើការចូលរួមក្នុងថ្នាក់....... ៧

១.៤. ផលប៉ះពាល់នៃការរៀនពីរជំនាញលើមធ្យមភាគសិក្សា (GPA) ....... ៨


## ជំពូកទី ២

## ស្ថានភាពនៃការអប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា


**២.១. ប្រវត្តិនៃការអប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា....... ១១**

២.១.១. សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)....... ១២

២.១.២. ប្រព័ន្ធអប់រំសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៩១)....... ១៣

២.១.៣. សម័យអ៊ុនតាក់ (UNTAC) និងរដ្ឋាភិបាលចំរុះ (១៩៩១-១៩៩៧)....... ១៥

២.១.៤. សម័យសម្តេចនាយករដ្ឋមន្ត្រីតេជោ ហ៊ុន សែន (១៩៩៨-២០១៣) ....... ១៧

**២.២. គោលនយោបាយអប់រំទូទៅ ២០១៤-២០១៨**

២.២.១. ការពង្រឹងគុណភាពវិស័យអប់រំ ....... ១៨

២.២.២. បញ្ហាប្រឈម និងដំណោះស្រាយក្នុងកំឡុងពេលនៃការអនុវត្តផែនការ
យុទ្ធសាស្ត្រវិស័យអប់រំ (២០០៩-២០១៣) ............ ១៩
២.២.៣. ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំង
ការបណ្តុះបណ្តាលបច្ចេកទេស ............ ២០
**២.៣. ការអប់រំ STEM នៅប្រទេសកម្ពុជា**
២.៣.១. ទិដ្ឋភាពរួមអំពីការអប់រំ STEM នៅប្រទេសកម្ពុជា ............ ២២
២.៣.២. សារៈសំខាន់នៃការអប់រំ STEM ............ ២៣
២.៣.៣. យុទ្ធសាស្ត្រក្នុងការជំរុញ STEM នៅប្រទេសកម្ពុជា ............ ២៤
**ជំពូកទី ៣**
**ការវិភាគទិន្នន័យ**
៣.១. ការវិភាគ និងបកស្រាយអត្ថន័យអថេរឯករាជ្យទាំងបួន ............ ២៦
៣.២. ការវិភាគ និងបកស្រាយទំនាក់ទំនងរវាងអថេរឯករាជ្យនិងមធ្យមភាគសិក្សា ............ ៣២
៣.៣. លទ្ធផលនៃការស្រាវជ្រាវ ............ ៣៦
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**
១. សេចក្តីសន្និដ្ឋាន ............ ៣៨
២. អនុសាសន៍ ............ ៣៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

**តារាង ១.១៖** ភាគរយនៃនិស្សិតដែលបានរាយការណ៍អំពីកម្រិតនៃសារៈសំខាន់នៃកត្តាផ្សេងៗជាច្រើន ដែលប៉ះពាល់ដល់ជម្រើសនៃការរៀនពីរជំនាញរបស់ពួកគេ....................................៥

**តារាង ២.១៖** ឈ្មោះសាកលវិទ្យាល័យក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា...................១៥

**តារាង ៣.១៖** Regression Model សង្ខេប ..........................................................................៣៩

**បញ្ជីក្រាហ្វិក**

**ក្រាហ្វិក ៣.១.៖**កត្តាដែលជំរុញឲ្យនិស្សិតសិក្សាពីរជំនាញក្នុងពេលតែមួយ ............................ ២៦
**ក្រាហ្វិក ៣.២.៖**ឥទ្ធិពលនៃការសិក្សាពីរជំនាញលើការចូលរួមក្នុងថ្នាក់របស់និស្សិត ................ ២៧
**ក្រាហ្វិក ៣.៣.៖**ឥទ្ធិពលនៃការសិក្សាពីរជំនាញលើចំណង់នៃការសិក្សារបស់និស្សិត .............. ២៨
**ក្រាហ្វិក៣.៤.៖**ទ្ធិពលនៃការសិក្សាពីរជំនាញលើការគ្រប់គ្រងពេលវេលារបស់និស្សិត ............. ២៩
**ក្រាហ្វិក៣.៥.៖**ឥទ្ធិពលនៃការសិក្សាពីរជំនាញលើស្ថានភាពសុខភាពរបស់និស្សិត ................. ៣០
**ក្រាហ្វិក ៣.៦.៖** មធ្យមភាគសិក្សា (GPA)របស់និស្សិតសិក្សាពីរជំនាញ.................................. ៣១
**ក្រាហ្វិក ៣.៧.៖** ឥទ្ធិពលនៃកត្តាជំរុញលើមធ្យមភាគសិក្សា (GPA) របស់និស្សិត ..................... ៣២
**ក្រាហ្វិក៣.៨.៖**ឥទ្ធិពលនៃការចូលរួមក្នុងថ្នាក់លើមធ្យមភាគសិក្សា(GPA) របស់និស្សិត........... ៣២
**ក្រាហ្វិក ៣.៩.៖** ឥទ្ធិពលនៃចំណង់នៃការសិក្សាលើមធ្យមភាគសិក្សា (GPA) របស់និស្សិត ....... ៣៣
**ក្រាហ្វិក ៣.១០.៖**ឥទ្ធិពលនៃការគ្រប់គ្រងពេលវេលាលើមធ្យមភាគសិក្សា(GPA)របស់និស្សិត .. ៣៤
**ក្រាហ្វិក៣.១១.៖**ឥទ្ធិពលនៃសុខភាពរបស់និស្សិតលើមធ្យមភាគសិក្សា(GPA)........................ ៣៥
**ក្រាហ្វិក៣.១២.៖**ចំណាប់អារម្មណ៍របស់និស្សិតទៅលើការសិក្សាពីរជំនាញ ............................ ៣៦

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា និងការកំណត់បញ្ហា

នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ចំនួននិស្សិតដែលកំពុងសិក្សាថ្នាក់ឧត្តមសិក្សាកំពុងតែកើនឡើងគួរឲ្យកត់សម្គាល់។ នៅឆ្នាំ១៩៦៥ មានសាកលវិទ្យាល័យតែ៦ប៉ុណ្ណោះនៅប្រទេសកម្ពុជា និងមាននិស្សិតចូលរៀនប្រហែល៧៣៦០នាក់ (James H. Williams, Yuto Kitamura, C. Sopcheak Keng, 2014) ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រឹះស្ថានឧត្តមសិក្សាបានកើនឡើងគួរឲ្យកត់សម្គាល់រហូតដល់ទៅ៨០កន្លែង ហើយមាននិស្សិតចុះឈ្មោះចូលរៀនកើនឡើងដល់ ២០៧ ០០០នាក់ចន្លោះពីឆ្នាំ ២០០៩ ដល់ ២០១៣ (Higher Education, n.d.)។

នៅពេលដែលការសិក្សាថ្នាក់ឧត្តមសិក្សាបានក្លាយជាទីចំណាប់អារម្មណ៍របស់និស្សិតកម្ពុជា ការសិក្សាពីរជំនាញក្នុងពេលតែមួយក៏បានក្លាយជាទីចំណាប់អារម្មណ៍របស់និស្សិតដែរ ដោយសារពួកគេជឿជាក់ថា ការសិក្សាពីរជំនាញអាចជួយឲ្យគេរកការងារដែលផ្តល់ប្រាក់ខែខ្ពស់ជាងការសិក្សាតែមួយជំនាញ (Roath, 2015)។ ទន្ទឹមនឹងការគិតបែបនេះ ពួកគេហាក់ដូចជាមិនបានចាប់អារម្មណ៍ពីផលប៉ះពាល់ដែលអាចកើតមានឡើងដោយសារការសិក្សាពីរជំនាញទេ ដូចជាបញ្ហាហិរញ្ញវត្ថុ បញ្ហាសុខភាព បញ្ហាពេលវេលា និងបញ្ហាលទ្ធផលនៃការសិក្សារបស់ពួកគេជាដើម។ ការស្រាវជ្រាវមួយនេះនឹងធ្វើការផ្តោតសំខាន់តែទៅលើឥទ្ធិពលនៃការសិក្សាពីរជំនាញ ទៅលើលទ្ធផលនៃការសិក្សាតែប៉ុណ្ណោះ។

ទោះបីជាការសិក្សាពីរជំនាញក្នុងពេលតែមួយបានកំពុងតែពេញនិយមក្នុងចំណោមនិស្សិតខ្មែរក៏ដោយ មិនមែននិស្សិតទាំងអស់សុទ្ធតែទទួលបានជោគជ័យក្នុងការសិក្សានោះទេ ពីព្រោះការសិក្សាពីរជំនាញទាមទារទាំងពេលវេលានិងការខិតខំប្រឹងប្រែងច្រើនអស់ពីកំលាំងកាយចិត្ត។ កន្លងមក មានការសិក្សាស្រាវជ្រាវមួយចំនួនបានធ្វើឡើងទាក់ទងនឹងការសិក្សាពីរជំនាញ ប៉ុន្តែវាគ្រាន់តែធ្វើការបង្ហាញអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការសិក្សាពីរជំនាញតែប៉ុណ្ណោះ។ លើសពីនេះ មិនទាន់មានការស្រាវជ្រាវណាមួយបានបង្ហាញឲ្យច្បាស់ថា តើការសិក្សាពីរជំនាញក្នុងពេលតែមួយមានឥទ្ធិពលវិជ្ជមានឬអវិជ្ជមានទៅលើលទ្ធផលនៃការសិក្សារបស់និស្សិតនៅឡើយទេ ពិសេសក្នុងក្របខណ្ឌប្រទេសកម្ពុជា។ ដូចនេះ ដើម្បីបំពេញនូវចន្លោះខ្វះខាតនេះ វាទាមទារចាំបាច់នូវការសិក្សាពីទំនាក់ទំនងមួយនេះ។

ការស្រាវជ្រាវមុនៗបានលើកឡើងថា នៅពេលសិស្សមានកិច្ចការសាលាធ្វើកាន់តែច្រើន ពួកគេនឹងបង្កើនការយកចិត្តទុកដាក់រៀនសូត្រ (Schachner, 2015) ហើយការរៀនពីរជំនាញក្នុងពេលតែមួយមានសារៈសំខាន់ណាស់ ប្រសិនបើមុខវិជ្ជាទាំងពីរនោះមានលក្ខណៈស្រដៀងគ្នា ហើយជួយបំពេញគ្នាទៅវិញទៅមក (Ciniro, 2014) ។ ពត៌មានទាំងនេះបានបង្ហាញខ្លះៗអំពីទំនាក់ទំនងរវាងការសិក្សាពីរជំនាញ និងការសិក្សារបស់សិស្សនិស្សិត។ ដោយសារលទ្ធផលនៃការសិក្សាពិតជាមានសារៈសំខាន់ណាស់ ចំពោះការសិក្សានៅថ្នាក់ក្រោយឧត្តមសិក្សា និងឱកាសការងារទៅថ្ងៃអនាគតរបស់និស្សិត ការស្រាវជ្រាវមួយនេះនឹងជួយផ្តល់ឲ្យនិស្សិតនូវពត៌មានក្នុងការសម្រេចចិត្តថា តើគួរសិក្សាពីរជំនាញដែរឬទេ តាមរយៈការថ្លឹងថ្លែងពីគុណសម្បត្តិ និងគុណវិបត្តិរបស់វាទៅលើឱកាសជោគជ័យនៃការសិក្សា។

## ២. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ *"ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយលើលទ្ធផលនៃការសិក្សារបស់និស្សិត"* មានគោលបំណងសំខាន់ធំៗពីរគឺ៖

- បង្ហាញនិងបកស្រាយអំពីមូលហេតុដែលជម្រុញឲ្យនិស្សិតសម្រេចចិត្តសិក្សាពីរជំនាញក្នុងពេលតែមួយ។
- បង្ហាញនិងពន្យល់ពីឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយទៅលើលទ្ធផលនៃការសិក្សារបស់និស្សិត។

## ៣. សំណួរស្រាវជ្រាវ

ផ្អែកតាមគោលបំណងនៃការស្រាវជ្រាវខាងលើ ការសិក្សាស្រាវជ្រាវមួយនេះនឹងធ្វើការឆ្លើយនូវសំណួរស្រាវជ្រាវគឺ៖

*"តើការសិក្សាពីរជំនាញក្នុងពេលតែមួយមានឥទ្ធិពលលើលទ្ធផលនៃការសិក្សារបស់និស្សិតយ៉ាងដូចម្តេច?"*

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

បើប្រៀបធៀបជាមួយប្រទេសជិតខាង ទំនោរនៃការសិក្សាពីរជំនាញក្នុងពេលតែមួយរបស់និស្សិតគឺជាចំណុចខុសប្លែកគ្នាមួយរវាងការអប់រំថ្នាក់ឧត្តមសិក្សានៅក្នុងប្រទេសកម្ពុជា និងប្រទេសដ៏ទៃ ដោយសារនៅប្រទេសដទៃទៀត ការសិក្សាពីរជំនាញក្នុងពេលតែមួយពុំសូវទទួលបានការចាប់អារម្មណ៍ពីនិស្សិតនោះទេ ឬក៏កម្រនឹងកើតមានតែម្តង។ ប៉ុន្តែ ការសិក្សាពីរជំនាញក្នុងពេលតែ

មួយមិនមែនជារឿងងាយស្រួលនោះទេ ដោយសារវាទាមទារពេលវេលា កំលាំងកាយ និងកម្លាំងចិត្តច្រើនណាស់ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រលើមុខជំនាញទាំងពីរប្រកបដោយជោគជ័យ។ ដោយសារតែភាពលំបាកនេះហើយ ទើបបានជាមាននិស្សិតមួយចំនួនសម្រេចចិត្តបោះបង់ចោលការសិក្សារបស់ខ្លួននៅពាក់កណ្តាលទី ហើយអ្នកខ្លះទៀតស៊ូទ្រាំបន្តការសិក្សាទាំងភាពសោកស្តាយដែលមិនគួរជ្រើសរើសរៀនពីរជំនាញ។

អាស្រ័យហេតុនេះហើយ ការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះនឹងផ្តល់ជាគុណប្រយោជន៍ធំៗចំនួនពីរគឺៈ

- ការយកលទ្ធផលសិក្សារបស់និស្សិតរៀនពីរជំនាញមកបង្ហាញដើម្បីផ្តល់ជាគំនិតពិចារណាដល់ប្អូននិស្សិតជំនាន់ក្រោយមុននឹងធ្វើការសម្រេចចិត្តសិក្សាពីរជំនាញក្នុងពេលតែមួយ។
- ការទាញចំណាប់អារម្មណ៍ និងបើកផ្លូវដល់ការស្រាវជ្រាវក្រោយៗទៀតលើបញ្ហាការសិក្សាពីរជំនាញក្នុងពេលតែមួយរបស់និស្សិតកម្ពុជា។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ ផ្តោតសំខាន់លើឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយទៅលើលទ្ធផលនៃការសិក្សារបស់និស្សិតតែប៉ុណ្ណោះ ដោយមិនផ្តោតទៅលើឥទ្ធិពលរបស់វាទៅលើកត្តាហិរញ្ញវត្ថុ និងសុខភាពរបស់និស្សិតឡើយ។ លើសពីនេះទៀត ការស្រាវជ្រាវនេះធ្វើឡើងដោយផ្តោតជាសំខាន់លើនិស្សិតកម្ពុជាដែលកំពុងសិក្សាពីរជំនាញក្នុងពេលតែមួយនៅកម្រិតថ្នាក់បរិញ្ញាបត្រនៅតាមសាកលវិទ្យាល័យមួយចំនួនក្នុងរាជធានីភ្នំពេញក្នុងឆ្នាំសិក្សា ២០១៦-២០១៧។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវមួយនេះ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យ (Quantitative Method) និងបានប្រើប្រាស់កម្រងសំណួរជាវិធីសាស្ត្រប្រមូលទិន្នន័យចម្បង (Primary Data) ពីនិស្សិតដែលកំពុងសិក្សាឆ្នាំទី២ រហូតដល់ឆ្នាំ ទី៤។ នៅក្នុងកម្រងសំណួរ មានសំណួរសរុបទាំងអស់ចំនួន១២សំណួរ ដែលក្នុងនោះ ៨សំណួរជាសំណួរបិទ និង៤សំណួរទៀតជាសំណួរបើក។

យើងបានជ្រើសយកសាកលវិទ្យាល័យធំៗ ចំនួនបីជាទីតាំងក្នុងការជ្រើសរើសយកនិស្សិតមកធ្វើជាគំរូតាងគឺ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យ

ភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យមេគង្គកម្ពុជា។ គំរូតាងគឺមាននិស្សិតសិក្សាពីរជំនាញក្នុងពេលតែមួយចំនួន៦០នាក់ ដែលក្នុងនោះ ២០នាក់មកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ២០នាក់ទៀតមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង២០នាក់ទៀតមកពីសាកលវិទ្យាល័យមេគង្គកម្ពុជា។ គំរូតាងនេះត្រូវបានជ្រើសរើសដោយប្រើប្រាស់វិធី "Snowball Sampling Technique"។ បន្ទាប់ពីទទួលបានទិន្នន័យដំបូង (Primary Data) ពីនិស្សិតទាំង៦០នាក់តាមរយៈកម្រងសំណួរមក ទិន្នន័យទាំងនោះត្រូវបានយកទៅចងក្រង និងវិភាគនៅក្នុងកម្មវិធី SPSS និង Microsoft Excel។ ក្រៅពីនេះ ប្រភពទិន្នន័យបន្ទាប់បន្សំសម្រាប់ជំនួយក្នុងការបកស្រាយ និងពន្យល់លទ្ធផលនៃការវិភាគក៏ត្រូវបានដកស្រង់ និងទាញយកពីប្រព័ន្ធអីនធឺណែតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាក្រោមប្រធានបទ "**ការសិក្សាពីរជំនាញក្នុងពេលតែមួយ**" ចែកចេញជាបីជំពូក។ **ជំពូកទី១៖ រំលឹកទ្រឹស្តីពាក់ព័ន្ធ-** ដែលផ្នែកនេះបានលើកយកទ្រឹស្តីមួយចំនួនមកបកស្រាយដូចជាកត្តាដែលជំរុញឲ្យនិស្សិតសិក្សាពីរជំនាញក្នុងពេលតែមួយ ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយលើឱកាសការងារ កម្រិតប្រាក់ចំណូល ការចូលរួមក្នុងថ្នាក់ និងមធ្យមភាគសិក្សារបស់និស្សិត។ **ជំពូកទី២៖ ស្ថានភាពការអប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា-** ដែលជំពូកនេះនឹងធ្វើការបកស្រាយអំពីប្រវត្តិនៃការអប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា បន្ទាប់មកទើបក្រលេកមើលពីទិដ្ឋភាពជាក់ស្តែងនៃទំនោរនៃការសិក្សា ក៏ដូចជាការរើសជំនាញរបស់និស្សិតកម្ពុជា និងចុងក្រោយនឹងពិនិត្យមើលអំពីវិធានការណ៍របស់រាជរដ្ឋាភិបាល ក្នុងកំណែទម្រង់វិស័យអប់រំនាពេលថ្មីៗនេះ ជាពិសេសទៅលើមុខវិជ្ជា STEM (Science, Technology, Engineering and Mathematics)។ **ជំពូកទី៣៖ ការវិភាគលទ្ធផលស្រាវជ្រាវ-** ដែលជាចំណុចចុងក្រោយ យើងនឹងធ្វើការវិភាគ និងបកស្រាយយ៉ាងលម្អិតនូវទិន្នន័យដែលប្រមូលបានដោយចងក្រងជាតារាង និងក្រាហ្វិកដើម្បីបំភ្លឺពីមូលហេតុចម្បងៗដែលជំរុញឲ្យនិស្សិតសម្រេចចិត្តជ្រើសរើសរៀនពីរជំនាញក្នុងពេលតែមួយ និងបង្ហាញពីលទ្ធផលនៃការសិក្សាដែលនិស្សិតរៀនពីរជំនាញទទួលបាន ផលវិបាកដែលពួកគេជួបប្រទះ និងមតិយោបល់របស់ពួកគេទៅកាន់ប្អូនៗនិស្សិតជំនាន់ក្រោយ។

# ជំពូកទី ១

# ទ្រឹស្តីដែលពាក់ព័ន្ធនឹងការសិក្សាពីរជំនាញក្នុងពេលតែមួយ

## ១.១. កត្តាដែលជំរុញឲ្យនិស្សិតសិក្សាពីរជំនាញក្នុងពេលតែមួយ

យោងតាមរបាយការណ៍មួយដែលមានចំណងជើងថា "ការសិក្សាពីរជំនាញ" បានលើកឡើងថាៈ

"មូលហេតុដែលនិស្សិតជ្រើសរើសសិក្សាពីរជំនាញគឺដោយសារពួកគេម្នាក់ៗ មានការលើកទឹកចិត្តផ្សេងៗគ្នា។ កត្តាជំរុញទឹកចិត្តសំខាន់ទីមួយគឺដើម្បីត្រៀមលក្ខណៈសម្បត្តិឱ្យហើយសម្រាប់ការងារនាពេលអនាគត ដែលក្នុងនោះមាននិស្សិត ៧៥.៨% បានសំរេចចិត្តរៀនពីរជំនាញដោយសារកត្តានេះ ខណៈពេលដែលមាននិស្សិតប្រមាណ ៧២.៣% ផ្សេងទៀតបានសម្រេចចិត្តរៀនពីរជំនាញដោយសារចំណង់ចំណូលចិត្តរបស់ខ្លួនឯង" (Richard & Steven , 2012, p. 24)។

យោងតាមប្រភពដដែល មាននិស្សិតខ្លះទៀត ប្រហែលជាង ៦០% រៀនពីរជំនាញដោយសារតែជំនាញទាំងពីររបស់ពួកគេមានលក្ខណៈបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដូច្នេះពួកគេអាចពង្រឹង និងពង្រីកជំនាញ ចំណេះដឹង សមត្ថភាពសម្រាប់ការប្រកួតប្រជែង ក៏ដូចជាចំណេះដឹងបន្ថែមដែលបានមកពីការរៀនមុខវិជ្ជាច្រើនផ្សេងៗគ្នា។ លើសពីនេះទៅទៀត និស្សិតមួយចំនួនតូចទៀតបានសំរេចចិត្តរៀនពីរជំនាញក្នុងពេលតែមួយ ដោយសារពួកគេគិតថា រៀនជំនាញទី១គឺជាជំនាញគោលសំខាន់ រីឯជំនាញទី២គឺរៀនគ្រាន់តែជាការកំសាន្ត ឬក៏រៀនតាមចំណង់របស់ឪពុកម្តាយដែលចង់ឱ្យពួកគេរៀនពីរជំនាញតែប៉ុណ្ណោះ។

**តារាង ១.១៖ បង្ហាញពីភាគរយនៃនិស្សិតដែលបានរាយការណ៍អំពីកម្រិតនៃសារៈសំខាន់នៃកត្តាផ្សេងៗជាច្រើនដែលមានឥទ្ធិពលលើជម្រើសនៃការរៀនពីរជំនាញរបស់ពួកគេ**

| មូលហេតុ | ភាគរយ |
|---|---|
| ដើម្បីរៀបចំខ្លួនដើម្បីឱកាសការងារ | ៧៦ |
| ដើម្បីបង្ហាញពីអត្តសញ្ញាណបុគ្គល | ៧២ |
| ដើម្បីរៀនមុខវិជ្ជាដែលជួយបំពេញគ្នាបាន | ៧០ |
| ដើម្បីកាន់តែមានភាពប្រកួតប្រជែងលើទីផ្សារការងារ | ៦៨ |
| ដើម្បីពង្រីកចំណេះដឹង | ៦៣ |

| | |
|---|---|
| ដើម្បីទទួលបានតម្លៃកាន់តែប្រសើរ | ៥៥ |
| ដើម្បីទទួលបានអត្ថប្រយោជន៍ពីCredit | 47 |
| មុខជំនាញមួយជាអាជីព និងមុខជំនាញមួយទៀតសម្រាប់កំសាន្ត | ៣៦ |
| មុខជំនាញមួយសម្រាប់ខ្ញុំ និងមួយទៀតសម្រាប់ម្តាយឪពុកខ្ញុំ | ១៣ |

ប្រភព៖ *A Curb Center Report at Vanderbilt University* ឆ្នាំ ២០១២

## ១.២. ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយលើឱកាសការងារ និងកម្រិតប្រាក់ចំណូល

នៅក្នុងសម័យកាលសាកលភាវូបនីយកម្មនេះ ទីផ្សារការងារកាន់តែមានភាពប្រកួតប្រជែងខ្លាំងឡើងៗដែលទាមទារឲ្យបុគ្គលម្នាក់ៗមានចំណេះដឹងទូលំទូលាយ មានជំនាញច្បាស់លាស់ និងសំបូរបែប មានគំនិតច្នៃប្រឌិតខ្ពស់ និងមានសមត្ថភាពធ្វើការងារប្រកបដោយគុណភាព និងប្រសិទ្ធ-ភាព។ អាស្រ័យហេតុនេះ ដើម្បីទទួលបានឱកាសការងារកាន់តែច្រើនដែលផ្តល់ប្រាក់ចំណូលខ្ពស់ និស្សិតបានខិតខំកសាងសមត្ថភាពខ្លួនឯងឲ្យកាន់តែមានលក្ខណៈប្រកួតប្រជែងខ្ពស់តាមរយៈការសិក្សាពីរជំនាញក្នុងពេលតែមួយនៅថ្នាក់ឧត្តមសិក្សា។ និស្សិតតែងសង្ឃឹមថា ការសិក្សាពីរជំនាញនឹងផ្តល់ឲ្យពួកគេនូវប្រាក់ចំណូលខ្ពស់ តាមរយៈជំនាញបន្ថែមដែលគេទទួលបាន និងលក្ខណៈសម្បត្តិមួយចំនួនទៀត ដែលមានឥទ្ធិពលវិជ្ជមានដល់ប្រសិទ្ធភាពការងារខ្ពស់ (Alison & Joni , 2007)។ លើសពីនេះទៀត ប្រភពដដែលបានបន្តថា ការសិក្សាពីរជំនាញអាចបង្កើនឱកាសកាន់តែច្រើនដល់និស្សិតនៅក្នុងទីផ្សារការងារ ប៉ុន្តែវាមិនមែនមានន័យថា ការសិក្សាពីរជំនាញសុទ្ធតែបង្កើនកម្រិតប្រាក់ចំណូលទាំងអស់នោះទេ។ ជាក់ស្តែង៖

"ការសិក្សាជំនាញពីរដែលមានលក្ខណៈស្រដៀងគ្នាខ្លាំង ឬការសិក្សាជំនាញពីរនៅក្នុងវិស័យវិស្វកម្ម វិទ្យាសាស្ត្រ និងគណិតសាស្ត្រ គឺទទួលបានកម្រិតប្រាក់ចំណូលដូចគ្នានឹងការសិក្សាតែមួយជំនាញ។ និស្សិតដែលសិក្សាពីរជំនាញមានកំណើនប្រាក់ចំណូល ២.៣% ច្រើនជាងនិស្សិតដែលសិក្សាតែមួយជំនាញ។ ផលចំណេញនេះ ភាគច្រើនបានមកពីការសិក្សាពីរជំនាញនៅក្នុងផ្នែកខុសគ្នា។ អ្នកដែលសិក្សាមុខជំនាញនៅក្នុងផ្នែកសិល្បៈ មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ហើយចាប់យកជំនាញមួយទៀតនៅក្នុងផ្នែកធុរៈកិច្ច វិស្វកម្ម វិទ្យាសាស្ត្រ ឬគណិតសាស្ត្រនឹងទទួលបានប្រាក់ចំណូលពី ៧% ទៅ ៥០% ច្រើនជាងអ្នកដែលរៀនតែមួយជំនាញនៅក្នុងផ្នែកសិល្បៈ មនុស្សសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម ប៉ុន្តែការរៀនពីរជំនាញបែបនេះមិនផ្តល់ប្រាក់ចំណូលច្រើនជាងការរៀនតែមួយជំនាញផ្នែកធុរៈកិច្ច វិស្វកម្ម វិទ្យាសាស្ត្រ ឬគណិតសាស្ត្រ

នោះទេ។ ចុងបញ្ចប់ ការរៀនពីរជំនាញបញ្ចូលគ្នារវាងធុរៈកិច្ច និងវិទ្យាសាស្ត្រ ឬគណិតសាស្ត្រ នឹងទទួលបានផលចំណេញ ៥០% ច្រើនជាងការរៀនតែមួយជំនាញនៅក្នុងផ្នែកនេះ" (Alison & Joni , 2007, p. 1) ។

## ១.៣. ឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយនៅលើការចូលរួមក្នុងថ្នាក់

ការសិក្សាពីរជំនាញ បានជះឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានដល់ការចូលរួមនៅក្នុងថ្នាក់របស់និស្សិត។ ចំពោះឥទ្ធិពលវិជ្ជមាន និស្សិតរៀនពីរជំនាញបានចូលរួមជាមួយការបង្ហាត់បង្ហាញរបស់គ្រូ និងទាញយកប្រយោជន៍បានច្រើនជាងនិស្សិតរៀនមួយជំនាញ។ យោងតាម (Richard & Steven , 2012) បានលើកឡើងថា៖

"៣៨%នៃនិស្សិតរៀនពីរជំនាញ បានចូលរួមក្នុងការបង្រៀនរបស់គ្រូ ខណៈពេលដែល ១៥%នៃសិស្សរៀនពីរជំនាញមានបញ្ហាជាមួយវត្តមានសិក្សា។ ។ បន្ថែមពីលើនេះ ធៀបនឹងនិស្សិតដែលរៀនតែមួយជំនាញ និស្សិតរៀនពីរជំនាញគឺសកម្មជាងក្នុងការចូលរួមសកម្មភាពនានារបស់សាលា មានឱកាសច្រើនជាងក្នុងការក្លាយជាមេក្រុមរបស់ក្លឹបសិក្សា សកម្មជាងនៅក្នុងការចូលរួមការងារស្ម័គ្រចិត្ត ជាពិសេសនៅពេលសំរាកវិស្សមកាល និងនៅក្នុងការធ្វើការស្រាវជ្រាវ"។

លើសពីនេះ ដោយសារការសិក្សាពីរជំនាញទាមទារការយកចិត្តទុកដាក់ខ្ពស់ និងត្រូវការពេលវេលាច្រើន និស្សិតរៀនពីរជំនាញតែងមានសមត្ថភាពប្រកួតប្រជែង និងអត់ធ្មត់ខ្ពស់។ ជាធម្មតា ពួកគេជឿជាក់លើខ្លួនឯង មានសណ្តាប់ធ្នាប់ មានសមាធិក្នុងការសិក្សា និងរៀបចំខ្លួនរួចជាស្រេចក្នុងការធ្វើការងារសាលាបន្ថែម។ នៅក្នុងសង្គមជាក់ស្តែង នយោជកមាននិន្នាការចង់បាននយោជិកដែលមានបទពិសោធន៍លើសពីជំនាញដែលពួកគេមាន។ ឧទាហរណ៍ជាក់ស្តែង Tim ដែលជានិស្សិតសិក្សាពីរជំនាញក្នុងពេលតែមួយ (សេដ្ឋកិច្ច និងភូមិវិទ្យា) បាននិយាយថា៖

"ជំនាញទាំងពីររបស់គាត់ធ្វើឲ្យគាត់មានលក្ខណៈសម្បត្តិលេចធ្លោជាងបេក្ខជនដទៃទៀត នៅពេលសម្ភាសន៍ការងារ ហើយក្រុមហ៊ុន ដែលគាត់កំពុងធ្វើការ ក៏ត្រូវការបុគ្គលិកដែលជំនាញអ្វីផ្សេងបន្ថែមពីលើជំនាញឯកទេសរបស់គេដែរ" ( (Richard & Steven , 2012, p. 26)។

និយាយដាច់ដោយឡែកទាក់ទងនឹងឥទ្ធិពលអវិជ្ជមាននៃការសិក្សាពីរជំនាញវិញ និស្សិតរៀនពីរជំនាញមានការរវល់ខ្លាំង និងត្រូវចំណាយពេលវេលាយ៉ាងច្រើនដើម្បីបញ្ចប់កិច្ចការសាលារបស់ពួកគេ ដែលជាហេតុធ្វើឲ្យពួកគេ ប្រឈមមុខនឹងការធុញថប់ ការព្រួយបារម្ភច្រើន និងបញ្ហាសុខភាពមួយចំនួនដូចជាឈឺក្បាល ផ្តាសាយ និងជម្ងឺដេកមិនលក់ជាដើម ដោយសារការរវល់រកពេលសំរាកគ្មាន ការខិតខំប្រឹងប្រែងហួសកំរិត និងការប្រឹងប្រែងឥតឈប់ឈររបស់និស្សិតមួយចំនួនដែលរៀននៅសាលាដែលមានការប្រកួតប្រជែងខ្លាំង។ យោងតាម ការស្ទង់មតិមួយរបស់

សមាគមសុខភាពមហាវិទ្យាល័យអាមេរិច (The American College Health Association) បានរាយការណ៍ថា ៣៩% នៃសិស្សមហាវិទ្យាល័យបានជួបប្រទះបញ្ហាធ្លាក់ទឹកចិត្តនៅក្នុងឆ្នាំសិក្សា ២៥% មានអារម្មណ៍ធុញថប់ និង ៤៧% ទៀតមានការព្រួយបារម្ភជ្រុល។ លើសពីនេះទៅទៀត នៅពេលរៀនពីរសាកលវិទ្យាល័យ និស្សិតត្រូវចំណាយពេលច្រើនសម្រាប់ធ្វើកិច្ចការស្រាវជ្រាវ ការងារសាលា និងវត្តមាននៅក្នុងថ្នាក់នីមួយៗ ដូច្នេះហើយ ពួកគេមិនអាចចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬការងារស្ម័គ្រចិត្តដែលផ្តល់ឱកាសច្រើនដល់ពួកគេក្នុងការទទួលបានការងារធ្វើ។ ជាក់ស្តែង មាននិស្សិត ២៥% យល់ថា ការរៀនពីរជំនាញបានកាត់បន្ថយឱកាសរបស់ពួកគេក្នុងការចូលរួមនៅក្នុងក្លឹបសិក្សា ឬកីឡា ខណៈពេលដែល ១៩% យល់ថា វាបានលើកកម្ពស់ឱកាសរបស់ពួកគេទៅវិញ (Richard & Steven , 2012) ។

## ១.៤. ផលប៉ះពាល់នៃការរៀនពីរជំនាញទៅលើមធ្យមភាគសិក្សា (GPA)

ក្រៅពីការជះឥទ្ធិពលលើការចូលរួមនៅក្នុងថ្នាក់របស់និស្សិត ការសិក្សាពីរជំនាញក៏ត្រូវបានគេចាត់ទុកថាជាកត្តាសំខាន់មួយដែលមានឥទ្ធិពលដល់មធ្យមភាគនៃការសិក្សា (GPA) របស់និស្សិតផងដែរ។ យោងតាមអត្ថបទនិយាយអំពីការរៀនពីរជំនាញនៅសហរដ្ឋអាមេរិចក្នុងឆ្នាំ ២០១៦ បានលើកឡើងថា និស្សិតដែលរៀនពីរជំនាញស្របពេលជាមួយគ្នាបានចូលរួមក្នុងសកម្មភាពផ្សេងៗជាច្រើន និងអាចប្រឹងប្រែងសិក្សានៅក្រៅថ្នាក់រៀនថែមទៀត (Double Majors in the United States, 2016)។ អត្ថបទដដែលបន្តទៀតថា ពួកគេទាំងនោះទទួលបាន GPA ខ្ពស់បើប្រៀបធៀបទៅនឹងនិស្សិតរៀនតែមួយជំនាញ។ ស្របគ្នានេះដែរ យោងតាមការស្ទង់មតិថ្នាក់ជាតិឆ្នាំ ២០០៣ នៃនិស្សិតបញ្ចប់មហាវិទ្យាល័យបានបង្ហាញថា អ្នករៀនពីរជំនាញជាមធ្យមទទួលបាន GPA ខ្ពស់ជាងអ្នករៀនតែមួយជំនាញ (Zafar, 2010)។ ក្រៅពីមធ្យមភាគនៃការសិក្សា (GPA) ការរៀនពីរជំនាញក្នុងពេលតែមួយជួយបង្កើនសមត្ថភាពនៃការរៀន និងការគិត និងជួយឲ្យនិស្សិតមានការគិតថ្មី និងគំនិតច្នៃ ប្រឌិតខ្ពស់ក្នុងការដោះស្រាយបញ្ហា និងបំពេញការងារស្រាវជ្រាវរបស់សាលា។ ជាឧទាហរណ៍ ទាក់ទងនឹងភាពច្នៃប្រឌិត និស្សិត ៦៤% បានរាយការណ៍ថា ការរៀនពីរជំនាញជួយលើកកម្ពស់សមត្ថភាពនៃការគិតរបស់ពួកគេ ខណៈពេលដែល ៨០% ទៀតគិតថា ការរៀនពីរជំនាញជួយអភិវឌ្ឍភាពវៃឆ្លាត និងចម្ងល់របស់ពួកគេ (Richard & Steven , 2012)។ បន្ថែមពីលើនេះទៀត ការស្ទង់មតិមួយដែលត្រូវបានគេធ្វើឡើងនៅឆ្នាំ ២០១៣ នៅសាកលវិទ្យាល័យ Vanderbilt បានរកឃើញថា និស្សិតដែលរៀនពីរជំនាញជាទូទៅមានគំនិត និងចំណេះដឹងទូទៅច្រើនជាងមិត្តភក្តិរបស់ពួកគេដែលរៀនតែមួយជំនាញ (Richard & Steven , 2012)។ ប្រភពដដែល

នេះបានធ្វើការស្ទង់មតិនិស្សិតពីរនាក់ដែលរៀនពីរជំនាញក្នុងពេលតែមួយ ហើយលទ្ធផលបានរកឃើញថា និស្សិតដែលរៀនពីរជំនាញ មានការគិតបែបស៊ីជម្រៅច្រើនជាងនិស្សិតដែលរៀនតែមួយជំនាញ។ លើសពីនេះទៅទៀត ការបញ្ចប់ការសិក្សាពីរជំនាញនៅពេលតែមួយជួយបង្កើនសមត្ថភាពគ្រប់គ្រងពេលវេលារបស់និស្សិត និងជំនាញក្នុងការគ្រប់គ្រងការងារច្រើនក្នុងពេលតែមួយ ពីព្រោះនិស្សិតត្រូវចេះរៀបចំកាលវិភាគ រៀបចំផែនការការងារ និងរៀនពីរបៀបធ្វើការងារច្រើនឲ្យមានប្រសិទ្ធភាព។

បើទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលនិស្សិតរៀនពីរជំនាញជាច្រើនពេញចិត្តនឹងពិន្ទុខ្ពស់របស់ពួកគេ ការសិក្សាជាច្រើនទៀតបានរកឃើញថា ការរៀនពីរជំនាញគឺជារឿងមិនល្អដែលនិស្សិតមិនគួរធ្វើឡើយ ដោយសារតែវាអាចប៉ះពាល់ដល់លទ្ធផលសិក្សា។ យោងតាម (Potter, 2016) បានលើកឡើងថា៖

"ការជ្រើសយកជំនាញតែមួយ គឺជាការគ្រប់គ្រាន់ណាស់ទៅហើយសម្រាប់និស្សិត។ ត្រឹមតែជំនាញមួយ វាទាមទារឲ្យនិស្សិតខិតខំប្រឹងប្រែងណាស់ ដើម្បីទទួលបានលទ្ធផលសិក្សាល្អ ឬពិន្ទុខ្ពស់ល្អ។ ដូច្នេះបានសេចក្តីថា វាមិនមែនជារឿងងាយស្រួលទេដែលថា សិស្សរៀនពីរជំនាញហើយទទួលបានពិន្ទុល្អទៀត"។

យោងតាម (Alison & Joni , 2007) បានលើកឡើងថា ការព្យាយាមបំពេញរាល់តម្រូវការរបស់ជំនាញច្រើនក្នុងពេលតែមួយ ធ្វើឲ្យនិស្សិតទទួលបានចំណេះដឹងមិនប្រាកដលើជំនាញណាមួយ ហើយថែមទាំងបន្ថយនូវចំណេះដឹងទូទៅទៀតផង។ ឧទាហរណ៍ និស្សិតម្នាក់បាននិយាយថាគាត់អស់កម្លាំងណាស់ ក្រោយពេលចេញពីរៀនក្នុងថ្នាក់ទាំងពីរ ហេតុនេះគាត់គ្មានកម្លាំងចិត្តសម្រាប់ភាពច្នៃប្រឌិតទេ។ អ្វីដែលគាត់ត្រូវធ្វើគឺព្យាយាមបញ្ចប់ការងារសាលា ហើយបន្តដើរទៅមុខទៀត (Richard & Steven, 2012)។

សរុបមក ការរៀនពីរជំនាញក្នុងពេលតែមួយពិតជាមានឥទ្ធិពលទាំងវិជ្ជមាននិងអវិជ្ជមានលើលទ្ធផលនៃការសិក្សារបស់និស្សិត។ បើទោះបីជា ការសិក្សាពីរជំនាញធ្វើឲ្យនិស្សិតសកម្មជាងនិងរៀនពូកែជាងពួកអ្នករៀនតែមួយជំនាញក៏ដោយ និស្សិតរៀនពីរជំនាញតែងជួបបញ្ហាដូចជាការរវល់ខ្លាំង និងបញ្ហាសុខភាព ដោយសារតែការសំរាកមិនបានគ្រប់គ្រាន់ ការមានអារម្មណ៍ធុញថប់ និងការព្រួយបារម្ភច្រើន។ លើសពីនេះ មិនមែនការសិក្សាពីរជំនាញទាំងអស់សុទ្ធតែផ្តល់អោយនិស្សិតនូវកំណើនប្រាក់ចំណូល និងឱកាសការងារច្រើននោះទេ។ យោងតាមទ្រឹស្តីខាងលើ និស្សិតដែលរៀនពីរជំនាញផ្នែកវិទ្យាសាស្រ្តសង្គមទាំងពីរជំនាញ នឹងទទួលបានប្រាក់ចំណូលច្រើនជាងអ្នកដែលរៀនតែមួយមុខជំនាញផ្នែកវិទ្យាសាស្រ្តសង្គម ប៉ុន្តែមិនច្រើនជាងអ្នករៀនតែមួយមុខ

ជំនាញផ្នែកវិទ្យាសាស្ត្រនោះទេ។ ជាចុងក្រោយ អ្នករៀនពីរជំនាញផ្នែកវិទ្យាសាស្ត្រទាំងពីរមុខជំនាញ នឹងទទួលបានប្រាក់ចំណូលច្រើនជាងអ្នករៀនតែមួយមុខជំនាញផ្នែកវិទ្យាសាស្ត្រ។

# ជំពូកទី ២
# ស្ថានភាពនៃការអប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា

## ២.១. ប្រវត្តិនៃការអប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាបានបង្កើតគ្រឹះស្ថានឧត្តមសិក្សាលើកដំបូងគេបំផុត នៅក្នុងសម័យអាណាចក្រអង្គរដែលជាចក្រភពដ៏មានអំណាចខ្លាំងក្លានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងសតវត្សទី ១២ (Sam, Ahmad & Hazri, 2012, p. 225)។ អត្ថបទនេះ បានបន្តទៀតថា នៅក្នុងកំឡុងពេលដ៏រុងរឿងនោះ ប្រទេសកម្ពុជាមានសាកលវិទ្យាល័យធំបំផុតចំនួនពីរគឺ វត្តជាយស្រី (Vat Cheysrey) ដែលស្ថិតនៅប្រាសាទព្រះខ័ន និងតារាវិហារ ដែលមានទីតាំងនៅប្រាសាទតាព្រហ្ម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះនាងឥន្ទ្រទេវី ដែលជាព្រះមហេសីរបស់ព្រះបាទជយវរ្ម័នទី៧ (១១៨១-១២២០)។ នៅសម័យនោះ ប្រាសាទមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យអប់រំ វប្បធម៌ និងសកម្មភាពច្នៃប្រឌិត។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាមានបេក្ខជនបណ្ឌិតចំនួន ១៨ នាក់ដែលជំនាញខាងវប្បធម៌ និងសាសនា និងមានគ្រូកម្រិតថ្នាក់សាកលវិទ្យាល័យចំនួន ៧៤០នាក់ ដែលមានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍ និងលើកកម្ពស់មូលធនមនុស្ស។

បន្ទាប់ពីការធ្លាក់ចុះនៃសម័យអង្គរនៅសតវត្សទី១៥ គ្រឹះស្ថានថ្នាក់ឧត្តមសិក្សារបស់ប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញ និងបិទទ្វារដោយសារតែសង្គ្រាមនិងការឈ្លានពានពីប្រទេសជិតខាងរួមមានថៃ និងវៀតណាម។ ក្នុងកំឡុងពេលដ៏លំបាកនោះ វត្តអារាមបានក្លាយទៅជាកន្លែងអប់រំយ៉ាងសំខាន់សម្រាប់អ្នកប្រាជ្ញ និងបញ្ញាវន្តខ្មែរ។ ដើម្បីបញ្ឈប់មហិច្ឆតាឈ្លានពានរបស់ប្រទេសទាំងពីរ ព្រះបាទអង្គដួង (១៧៩៧-១៨៦០) ក៏បានអញ្ជើញបារាំងមកធ្វើជាអាណាព្យាបាលឆ្នាំ១៨៦៣។ ក្រោមកិច្ចការពាររបស់អាណាព្យាបាល បារាំងបានព្យាយាមផ្លាស់ប្តូរប្រព័ន្ធអប់រំរបស់កម្ពុជាដែលមានលក្ខណៈប្រពៃណីឲ្យទៅជាប្រព័ន្ធអប់រំមួយ ដែលមានលក្ខណៈបែបទំនើបរបៀបពួកលោកខាងលិច។ លើសពីនេះទៅទៀត សាលារដ្ឋ និងគ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សាជាច្រើនត្រូវបានបង្កើតឡើងទូទាំងប្រទេសកម្ពុជា។ ក្នុងសម័យក្រោយអាណានិគម សម្តេចព្រះនរោត្តមសីហនុបានយកចិត្តទុកដាក់លើការអប់រំថ្នាក់ឧត្តមតាមរយៈការសាងសង់គ្រឹះស្ថានសិក្សាថ្នាក់ឧត្តមជាច្រើនកន្លែងនៅទូទាំងប្រទេសកម្ពុជា។ គួរឲ្យសោកស្តាយបំផុត ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមត្រជាក់នៅឆ្នាំ១៩៧០ ដែលនាពេលនោះ ការអប់រំថ្នាក់ឧត្តមសិក្សាត្រូវបានបំផ្លាញស្ទើរទាំង

ស្រុង។ សោកនាដកម្មដ៏ធំបំផុតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ចន្លោះឆ្នាំ ១៩៧០-១៩៧៩ បញ្ញាវន្តខ្មែរ អ្នកប្រាជ្ញ និងអ្នកចេះដឹងជាច្រើនត្រូវបានបាត់បង់នៅក្នុងរបបប្រល័យពូជសាសន៍នោះ។ ក្រោយពីសង្គ្រាមស៊ីវិល ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ ១៩៩៨ កម្ពុជាបានខិតខំយ៉ាងខ្លាំងក្នុងការអភិវឌ្ឍ និងធ្វើកំណែទម្រង់ប្រពន្ធ័អប់រំថ្នាក់ឧត្តមសិក្សារហូតមកដល់បច្ចុប្បន្ន។

ប្រពន្ធ័អប់រំថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជាត្រូវបានចែកចេញជា ៩ដំណាក់កាល ដោយគិតត្រឹមសម័យកម្ពុជាប្រជាធិបតេយ្យមក ដែលដំណាក់កាលនីមួយៗបង្ហាញពីមនោគមវិជ្ជា និងរបបនយោបាយផ្សេងគ្នាៗនៃប្រវត្តិប្រទេសកម្ពុជា។ ប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់មនោគមវិជ្ជា និងប្រពន្ធ័នយោបាយជាច្រើនដូចជា របបប្រពៃណីនិយម របបអាណានិគម របបរាជានិយម របបសាធារណៈរដ្ឋ និងរបបប្រជាធិបតេយ្យកូនកាត់ជាដើម។ ប្រវត្តិលំអិតនៃដំណាក់កាលនីមួយៗ មានដូចខាងក្រោម៖

### ២.១.១. សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់ប្រទេសកម្ពុជានៅថ្ងៃទី ១៧ មេសា ១៩៧៥ ភ្លាមនោះ ប៉ុល ពត បានចាប់ផ្តើមបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានដឹកនាំដោយគណៈបក្សកុំម្មុយនីស្តប្រជាធិបតេយ្យ ដោយយកគំរាប់តាមបដិវត្តន៍វប្បធម៌នៃសាធារណៈរដ្ឋប្រជាមានិតចិន ដែលបានអនុវត្តគោលនយោបាយជាតិបែបខ្លួនទីពឹងខ្លួន និងខ្លួនដឹកនាំខ្លួន ដើម្បីប្តូរប្រទេសកម្ពុជាឲ្យទៅជាប្រទេសកសិកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចខ្លួន។ ទោះបីជារដ្ឋាភិបាលបានបង្កើតសាលាយ៉ាងច្រើនក៏ដោយ ពួកគេគ្រាន់តែផ្តល់ការអប់រំកម្រិតមូលដ្ឋាន សម្រាប់គោលបំណងមនោគមនយោបាយរបស់ពួកគេ ដើម្បីសម្រេចគោលនយោបាយបដិវត្តកសិកម្ម (Ayres D. , 1999, pp. 205-208)។ អស់រយៈពេលជាង ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ របបខ្មែរក្រហម ត្រូវបានដួលរលំជាប្រពន្ធ័ដោយរួមមានទាំងវប្បធម៌ សេដ្ឋកិច្ច និងនយោបាយ (Chendler, 2008)។ គ្រឹះស្ថានថ្នាក់ឧត្តមសិក្សានៅប្រទេសកម្ពុជា មានភាពអន់ថយខ្លាំងបំផុត។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជាប្រមាណជា ១.៧លាននាក់ ត្រូវបានសំលាប់ដោយការកាត់ទោសប្រហារជីវិត ដោយការធ្វើការងារហួសកម្លាំង ការអត់ឃ្លាន និងជំងឺរាតត្បាតផ្សេងៗ។ ឧបករណ៍សម្រាប់ការអប់រំ ត្រូវបានបំផ្លាញស្ទើរតែទាំងស្រុង ហើយ ៧៥% នៃសាស្ត្រាចារ្យថ្នាក់ឧត្តមសិក្សា និង ៩៦% នៃនិស្សិតសាកលវិទ្យាល័យត្រូវបានបាត់បង់ជីវិត នៅក្នុងរបបប្រល័យពូជសាសន៍ (Pit & Ford, 2004)។ មុនសម័យខ្មែរក្រហមកម្ពុជាមានសាលាបឋមសិក្សាចំនួន ៥,២៧៥ អនុវិទ្យាល័យចំនួន ១៤៦ និងគ្រឹះស្ថានឧត្តមសិក្សា

ចំនួន ៩កន្លែង ប៉ុន្តែផ្ទុយទៅវិញ ប្រមាណ ៩០% នៃឧបករណ៍សិក្សា និងឯកសារសម្រាប់សិក្សាជាច្រើនទៀត ត្រូវបានបំផ្លាញទាំងស្រុងនៅក្នុងរបបខ្មែរក្រហម។

យោងតាម Vickery (1984) ប៉ុល ពត បានបង្កើតគោលនយោបាយអប់រំមួយដែលមានឈ្មោះថា ផែនការរយៈពេល ៤ ឆ្នាំ ១៩៧៦ (១៩៧៦-១៩៨០) ដើម្បីបង្កើតសង្គមនិយម នៅគ្រប់ទិសទីដែលតម្រូវឲ្យក្មេងៗ ត្រូវចូលរៀនយ៉ាងហោចណាស់ឲ្យបានបីឆ្នាំនៅក្នុងកម្មវិធីថ្នាក់បឋមសិក្សា។ ប៉ុល ពត មានចក្ខុវិស័យជ្រុលនិមយ ដោយចង់ផ្លាស់ប្ដូរការអប់រំរបស់និស្សិតខ្មែរពីការមិនចេះអក្សរសោះឲ្យក្លាយជាវិស្វករក្នុងរយៈពេលខ្លីបំផុតត្រឹមដប់ឆ្នាំ តាមរយៈការបណ្ដុះបណ្ដាល និងការអនុវត្តការងារជាក់ស្ដែង។ ពាក្យស្លោកដ៏ពេញនិយមបំផុតនៅសម័យនោះគឺ ការរៀនសូត្រ មិនសំខាន់ឡើយ។ អ្វីដែលសំខាន់គឺ ការងារ និងការធ្វើបដិវត្តន៍។ ផ្អែកលើ (Chendler, 2008) ខ្មែរក្រហមបានព្រងើយកន្តើយគុណភាពនៃការអប់រំ ដោយជ្រើសរើសយកប្រជាជនមិនចេះអក្សរមកធ្វើជាគ្រូ ដោយផ្ដោតលើសេចក្ដីស្មោះត្រង់ និងតំណែងរបស់ពួកគេនៅក្នុងជួរបដិវត្តន៍។ លើសពីនេះទៅទៀត របបខ្មែរក្រហម បានផលិតចំរៀងបដិវត្តន៍ជាច្រើន ដែលបង្ហាញពីការលះបង់ជូនជាតិ នៅក្នុងកម្មវិធីសិក្សាផ្នែកអំនាន សំណេរ គណិតសាស្ត្រ ភូមិសាស្ត្រ វិទ្យាសាស្ត្រធម្មជាតិ រូបវិទ្យា គីមីវិទ្យា ប្រវត្តិសាស្ត្រប្រទេសកម្ពុជា គណៈបក្សនយោបាយ និងទស្សនៈសីលធម៌ជាដើម ដើម្បីផ្លាស់ប្ដូរសិស្សនិស្សិត និងដើម្បីបន្សុទ្ធការយល់ដឹងនយោបាយរបស់ពួកគេ (Ayres D. , 1999)។ ជារួម ការបរាជ័យរបស់មនោគមកុំម្មុយនីស្តជ្រុលនិយមរបស់ខ្មែរក្រហម និងគោលនយោបាយអប់រំរបស់ខ្លួនបានទាញកម្ពុជាទៅរកចំណុចសូន្យឡើងវិញ នៃការកសាងការអប់រំនៅក្នុងប្រទេស។

### ២.១.២. ប្រពន្ធ័អប់រំសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៩១)

បន្ទាប់ពីសម័យខ្មែរក្រហម បានដួលរលំនៅឆ្នាំ ១៩៧៩ គឺត្រូវបានជំនួសមកវិញដោយរបបថ្មីមួយដែលគេហៅថា សាធារណៈរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានដឹកនាំដោយគណៈបក្សបដិវត្តន៍ប្រជាជនកម្ពុជា ដែលត្រូវបានដឹកនាំដោយសម្ដេច ហេង សំរិន (សព្វថ្ងៃលោកជាប្រធានរដ្ឋសភាជាតិកម្ពុជា)ដោយមានគាំទ្រពីកងកំលាំងវៀតណាម។ ក្នុងកំឡុងពេលឈ្លានពាន និងការកាន់កាប់របស់ប្រទេសវៀតណាម សង្គ្រាមបានពន្យារពេលជាច្រើនឆ្នាំនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងកំឡុងពេលដ៏លំបាកលំបិននោះ សាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានចាប់ផ្ដើមស្តារឡើងវិញនូវប្រព័ន្ធអប់រំ ដោយអំពាវនាវអ្នករស់រានមានជីវិតទាំងឡាយមកធ្វើជាគ្រូបង្រៀន និងជាអ្នកបណ្ដុះបណ្ដាលនៅសាលារៀន និងគ្រឹះស្ថានឧត្តមសិក្សា។ យោងតាមលោក ហ៊ុន សែន រដ្ឋាភិបាលបានអនុវត្តគោលនយោបាយរបស់ខ្លួន អ្នកចេះតិច បង្រៀនអ្នកមិនចេះសោះ អ្នកចេះច្រើន បង្រៀន

អ្នកចេះតិច (Sen, 2011)។ គ្រឹះស្ថានអប់រំបច្ចេកទេសថ្នាក់ឧត្តមសិក្សាសម័យនោះបានអនុវត្តប្រព័ន្ធកូនកាត់ពីសហភាពសូវៀត វៀតណាម និងប្រទេសប្លុកលោកខាងកើត។ គ្រឹះស្ថានអប់រំឧត្តមសិក្សាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងនយោបាយ ដើម្បីជម្រុញមនោគមវិជ្ជាសង្គមនិយម។ ដើម្បីសម្រេចគោលដៅនេះ និស្សិតថ្នាក់ឧត្តមសិក្សាត្រូវបានតម្រូវឲ្យរៀនមុខវិជ្ជាសំខាន់ចំនួនប្រាំ រួមមានទ្រឹស្តីម៉ាក់លេនីន (Marxist Leninist Theories) ប្រវត្តិបដិវត្តន៍កម្ពុជានិងសាកលលោក ស្ថានភាពនិងតួនាទីនៃបដិវត្តន៍ និងគោលនយោបាយរបស់បក្សការអប់រំសីលធម៌ និងមាគ៌ាបដិវត្តន៍នៃជីវិត និង ឥរិយាបថឆ្ពោះទៅរកភាពរួមមួយ (Clayton, 1999)។ នៅខែ ធ្នូ ១៩៧៩ មហាវិទ្យាល័យ ឱសថសាស្ត្រ និងទន្តសាស្ត្រ ដែលជាគ្រឹះស្ថានអប់រំឧត្តមសិក្សាទីមួយត្រូវបានបង្កើតឡើង។ មានវេជ្ជបណ្ឌិត ប្រមាណ ១០ ទៅ ២០ នាក់ មកពីក្រសួងសុខាភិបាលវៀតណាម បានមកផ្តល់ការអប់រំបណ្តុះបណ្តាលដល់និស្សិតខ្មែរដែលមិនទាន់បានបញ្ចប់ការសិក្សាផ្នែកឱសថសាស្ត្ររបស់ពួកគេមុនរបបកម្ពុជាប្រជាធិបតេយ្យ។ មហាវិទ្យាល័យបានផ្តល់កម្មវិធីសិក្សាអប់រំផ្នែកឱសថសាស្ត្រដែលមានរយៈពេល ៦ ឆ្នាំ។ នៅខែ កក្កដា ១៩៨០ មហាវិទ្យាល័យបណ្តុះបណ្តាលគ្រូត្រូវបានបង្កើតឡើង ដែលមានសាស្ត្រាចារ្យជនជាតិវៀតណាម ដែលមកពីក្រសួងអប់រំវៀតណាម មកបង្រៀននិស្សិតកម្ពុជាដែលមិនទាន់បានបញ្ចប់ការសិក្សារបស់ពួកគេពីគ្រឹះស្ថានអប់រំឧត្តមសិក្សាមុនឆ្នាំ ១៩៧៥។ គ្រឹះស្ថាននោះបានផ្តល់កម្មវិធីសិក្សាដែលមានរយៈពេលបីឆ្នាំ ដើម្បីក្លាយជាគ្រូនៅថ្នាក់វិទ្យាល័យ។ ខែកញ្ញា ឆ្នាំ ១៩៨១ វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាព ខ្មែរ-សូវៀត ត្រូវបានបង្កើតឡើងដោយមានការជួយគាំពារទាំងស្រុងពីសហភាពសូវៀតក្នុងផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងផ្នែកធនធានមនុស្ស។ មានសាស្ត្រាចារ្យសូវៀត ប្រហែល ៥៦នាក់មកបង្រៀនជំនាញសំខាន់ៗចំនួនប្រាំមួយ រួមមាន វិស្វករសំណង់ស៊ីវិល វិស្វករអគ្គិសនីនិងអេឡិចត្រូនិច គីមីឧស្សាហកម្ម វារីកសិកម្ម (Agro-Hydrology) ឧស្សាហកម្មរ៉ែ និង ភូគម្ពសាស្ត្រ ពីឆ្នាំ ១៩៨០ ដល់ឆ្នាំ ១៩៨៩។ លើសពីនេះទៀត វិទ្យាស្ថានសេដ្ឋកិច្ច ត្រូវបានបង្កើតឡើង នៅខែ កញ្ញា ឆ្នាំ ១៩៨៥ ដោយមានការជួយទ្រទ្រង់ទាំងស្រុងពីវៀតណាម ដែលបានផ្តល់គ្រូ សៀវភៅសិក្សា ក៏ដូចជាកម្មវិធីសិក្សាផងដែរ។ សាស្ត្រាចារ្យជនជាតិវៀតណាម ប្រហែល ៣០ ទៅ ៤០នាក់ ដែលបានមកពីសាកលវិទ្យាល័យសេដ្ឋកិច្ច នៅទីក្រុងហានូយ (Hanoi) បានបង្រៀនជំនាញប្រាំ រួមមាន សេដ្ឋកិច្ចកសិកម្ម សេដ្ឋកិច្ចឧស្សាហកម្ម ពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងការធ្វើផែនការសេដ្ឋកិច្ច។ ខែ មករា ឆ្នាំ ១៩៨៥ ត្រូវបានបង្កើតឡើង ក្រោមការជួយជ្រោមជ្រែង ក្នុងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីសាលាកសិកម្មអ៊ុយក្រែន (Ukraine Agricultural Academy)។ សាស្ត្រាចារ្យ ប្រហែល៥៦នាក់

ដែលមកពី សាកលវិទ្យាល័យផ្សេងៗក្នុងសហភាពសូវៀត បានមកបង្រៀនលើជំនាញប្រាំ រួមមាន កេ្សត្រ-សាស្ត្រ រុក្ខាប្រមាញ់ ជលផល បសុពេទ្យ និង វេជ្ជសាស្ត្រកសិកម្ម។ បន្ថែមពីនេះ មាននិស្សិតខ្មែរជាច្រើន ត្រូវបានបញ្ជូនទៅរៀននៅក្រៅប្រទេសតាមរយៈកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការ និងការអប់រំ។ ផ្អែកលើ Virak (2009) និស្សិតខ្មែរ ៦៥០៩នាក់ ត្រូវបានបញ្ជូនទៅរៀននៅប្រទេសក្រៅ ចន្លោះឆ្នាំ ១៩៧៩ ដល់ ១៩៨៩ នៅក្នុងនោះ មាននិស្សិតស្រី ១៤២៦នាក់។ និស្សិតកម្ពុជា ដែលទទួលបានអាហារូបករណ៍ ទៅសិក្សានៅក្រៅប្រទេស រួមមាន ១៥៩នាក់ ទៅប្រទេស ប៊ុលការី (Bulgaria) ៦០ ទៅគុយបា (Cuba) ៣០០ នាក់ទៅសាធារណៈរដ្ឋឆែក (Czech Republic) ១១៧៩ ទៅអាឡឺម៉ង់ខាងកើត ១៩១នាក់ ទៅហុងគ្រី ២៥នាក់ ទៅសាធារណៈរដ្ឋប្រជាមានិតឡាវ ៣០នាក់ ទៅម៉ុងហ្គោលី ៨០នាក់ ទៅប៉ូឡូញ ៣៧៣០នាក់ ទៅប្រទេសរ៉ុស្ស៊ី ៧៥១នាក់ ទៅប្រទេសវៀតណាម (Virak, 2009)។ នៅឆ្នាំ ១៩៨៩ សាធារណៈរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានប្តូរឈ្មោះទៅជា រដ្ឋកម្ពុជា បន្ទាប់ពីការដកចេញនៃកងទ័ពវៀតណាម និងការដួលរលំនៃសហភាពសូវៀត។ ត្រឹមឆ្នាំ ១៩៩០ និស្សិត ៩៧៧ នាក់ បានបញ្ចប់ការសិក្សាគ្រឹះស្ថានអប់រំឧត្តមសិក្សាកម្ពុជា ហើយបានក្លាយជាវេជ្ជបណ្ឌិត ទន្តពេទ្យ ឱសថការី ២១៩៦នាក់ បានក្លាយជាគ្រូនៅវិទ្យាល័យ ១៤៨១នាក់ បានក្លាយជាអ្នកជំនាញភាសាបរទេស ៤៧៤នាក់ បានក្លាយជាវិស្វករជំនាញបច្ចេកទេស ៤០០នាក់ ក្លាយជាអ្នកសេដ្ឋកិច្ច និង ១៨៤នាក់ទៀត បានក្លាយជា វិស្វករកសិកម្ម។ និយាយរួម គ្រឹះស្ថានអប់រំឧត្តមសិក្សាក្នុងកំឡុងពេលវៀតណាមកាន់កាប់ ត្រូវបានគ្រប់ដណ្តប់ដោយមនោគមវិជ្ជានយោបាយបែបសង្គមនិយម និងគុណភាពអប់រំអន់ថយ និងការអប់រំសម័យនោះ ពឹងផ្អែកទាំងស្រុងលើការជួយទ្រទ្រង់ទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីប្រទេសដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងមិត្តភាព។

**តារាង ២.១.៖ បង្ហាញពីឈ្មោះសាកលវិទ្យាល័យក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា**

| ល.រ | **សាកលវិទ្យាល័យ** | **កាលបរិច្ឆេទ** |
|---|---|---|
| ១ | មហាវិទ្យាល័យឱសថសាស្ត្រ និងទន្តសាស្ត្រ<br>The Faculty of Medicine and Dentistry(FMD) | ធ្នូ ១៩៧៩ |
| ២ | មហាវិទ្យាល័យបណ្តុះបណ្តាលគ្រូ<br>The Teacher Training College (TTC) | កក្កដា ១៩៨០ |
| ៣ | វិទ្យាស្ថានបច្ចេកទេសកម្រិតខ្ពស់សហភាពខ្មែរ-សូវៀត<br>The Khmer Soviet Friendship Higher Technical Institute | កញ្ញា ១៩៨១ |

| | | |
|---|---|---|
| ៤ | វិទ្យាស្ថានសេដ្ឋកិច្ច<br>The Institute of Economics (IE) | កញ្ញា ១៩៨៤ |
| ៥ | វិទ្យាស្ថានកសិកម្ម<br>The Institute of Agriculture (IA) | មករា ១៩៨៥ |

ប្រភព៖ Cambodia's Higher Education Development in Historical Perspectives (1863-2012)

### ២.១.៣. សម័យអ៊ុនតាក់ (UNTAC) និងរដ្ឋាភិបាលចំរុះ (១៩៩១-១៩៩៧)

ក្នុងសម័យនេះ វាគឺជាពេលវេលានៃការចាប់ផ្តើមសារជាថ្មីម្តងទៀតនៃការធ្វើកំណែទម្រង់ការរៀបចំរចនាសម្ពន្ធ័ និងការអភិវឌ្ឍគ្រឹះស្ថានអប់រំឧត្តមសិក្សានៅកម្ពុជា។ បន្ទាប់ពីសង្គ្រាមស៊ីវិលអស់ពេលមួយទសវត្ស និងរយៈពេលពីឆ្នាំនៃការចរចាបក្សដែលមានជម្លោះនៅកម្ពុជា ដែលរួមមានគណបក្សប្រជាជនកម្ពុជា កម្ពុជាប្រជាធិបតេយ្យ គណបក្សហ្វ៊ុនស៊ិនប៊ិច និងរណៈសិរ្សរំដោះជាតិរំដោះប្រជាពលរដ្ឋ បានចុះហត្ថលេខាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី ២៣ តុលា ១៩៩១ ដែលត្រូវបានផ្តួចផ្តើមធ្វើដោយអង្គការសហប្រជាជាតិ ដើម្បីបញ្ចប់សង្គ្រាមដ៏រាំរ៉ៃនៅកម្ពុជា (UNESCO, 2011)។ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតអាជ្ញាធរអន្តរកាលអង្គការសហប្រជាជាតិនៅក្នុងប្រទេសកម្ពុជា (UNTAC) ដើម្បីធានាការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពនោះ និងការរៀបចំការបោះឆ្នោតដោយសេរី និងយុត្តិធម៌។

ក្នុងកំឡុងពេលនៃការផ្លាស់ប្តូរពីឆ្នាំ ១៩៩១ ដល់ ១៩៩៣ ការអប់រំមានការប្រែប្រួលតិចតួចដែលធ្វើឡើងដោយ UNTAC ដោយសារតែរដ្ឋាភិបាលនៅតែរក្សាការគ្រប់គ្រងលើរដ្ឋបាលនៃវិស័យអប់រំដែលមានស្រាប់។ បន្ទាប់ពីការបោះឆ្នោតជាតិ ឆ្នាំ ១៩៩៣ រដ្ឋធម្មនុញ្ញថ្មី និងរដ្ឋាភិបាលចំរុះមួយត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលការរៀបចំ និងការអនុវត្តគោលនយោបាយជាតិ។ រដ្ឋាភិបាលថ្មីបានប្រកាសប្តេជ្ញាចិត្ត ដើម្បីអភិវឌ្ឍធនធានមនុស្ស និងការកសាងសមត្ថភាពរបស់ខ្លួនដោយបង្កើនយ៉ាងហោចណាស់ ១៥% នៃចំណាយសាធារណៈនៃថវិកាជាតិទាំងមូលទៅលើការអប់រំ បើទោះបី វាបានធ្លាក់ចុះពី ១១.៨% ឆ្នាំ ១៩៩៦-១៩៩៧ ទៅ ៨.៣% ឆ្នាំ១៩៩៨-១៩៩៩ (Ayres, 2000)។ ក្នុងឆ្នាំ១៩៩៤ រដ្ឋាភិបាលរួមជាមួយដៃគូអភិវឌ្ឍអន្តរជាតិបានបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍជាតិមួយ ដែលមានចំណងជើងថា កម្មវិធីជាតិដើម្បីស្តារ និងអភិវឌ្ឍកម្ពុជា (National program to rehabilitate and develop Cambodia) ដែលក្នុងនោះ ការអភិវឌ្ឍធនធានមនុស្សគឺជាផ្នែកមួយនៃសសរស្តម្ភរបស់កម្មវិធីនោះ។ គម្រោងមួយរបស់កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (UNDP)

ដែលសំដៅលើការកសាងសមត្ថភាពសម្រាប់ការអប់រំ និងការគ្រប់គ្រងវិស័យធនធានមនុស្ស ដែលជួយគាំទ្រដល់រដ្ឋាភិបាល គឺទីបំផុតត្រូវបានបំលែងទៅជាកម្មវិធីដើម្បីស្តាបនាឡើងវិញនូវគុណភាពអប់រំ និងការបណ្តុះបណ្តាលក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់សច្ចាប័នរបស់រដ្ឋាភិបាលនៅក្នុងអង្គសិក្ខាសាលាអប់រំជាតិក្នុងខែ មករា ឆ្នាំ ១៩៩៤។ គម្រោងចំនួនពីររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលរួមមាន ផែនការវិនិយោគអប់រំជាមូលដ្ឋាន(១៩៩៥-២០០០) និង ផែនការវិនិយោគអប់រំត្រូវបានអនុម័តដោយរដ្ឋាភិបាលកាលពី ខែធ្នូ ឆ្នាំ១៩៩៤ ហើយត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាលើកដំបូងរបស់ប្រទេសកម្ពុជា (១៩៩៦-២០០០)។ លើសពីនេះទៅទៀត រដ្ឋាភិបាលបានផ្លាស់ប្តូរគោលនយោបាយចម្បងៗ ចំនួនពីរនៃគ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សាក្នុងឆ្នាំ ១៩៩៧។ ទីមួយ រដ្ឋាភិបាលបានអនុញ្ញាតឲ្យគ្រឹះស្ថានអប់រំឧត្តមសិក្សារដ្ឋបើកថ្នាក់សិក្សាបង់ថ្លៃសម្រាប់និស្សិត ដែលមិនទទួលបានអាហារូបករណ៍ក្នុងបរិមាណកំណត់មួយរបស់គ្រឹះស្ថាននីមួយៗ។ លើសពីនេះទៀត និស្សិតពូកែដែលទទួលបានអាហារូបករណ៍រដ្ឋាភិបាលត្រូវបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា។ ទីពីរ រដ្ឋាភិបាលបានអនុញ្ញាតឲ្យវិស័យឯកជនចូលរួមវិនិយោគលើការអប់រំថ្នាក់ឧត្តមសិក្សា (Pit & Ford, 2004)។ Virak (2009) បានកំណត់សំគាល់ថា ចន្លោះឆ្នាំ ១៩៨៩ ដល់ ១៩៩៩ និស្សិតកម្ពុជា ចំនួន ២១៧០ នាក់ ត្រូវបានផ្តល់អាហារូបករណ៍ទៅសិក្សាក្រៅប្រទេស ដែលក្នុងនោះមាននិស្សិតស្រីចំនួន ១៨៧ នាក់។ ប្រភពដដែលបានបង្ហាញថា និស្សិត ១១២ នាក់បានទៅប្រទេសអូស្ត្រាលី ២៤ នាក់បានទៅប្រទេសកាណាដា ២២ នាក់បានទៅសាធារណៈរដ្ឋឆែកហ្ស ៣២ នាក់បានទៅប្រទេសបារាំង ១៤៨នាក់បានទៅប្រទេសអាឡឺម៉ង់ ៤ នាក់បានទៅប្រទេសហុងគ្រី ២០ នាក់បានទៅប្រទេសឥណ្ឌូនេស៊ី ១៤២ នាក់បានទៅប្រទេសជប៉ុន ១០ នាក់បានទៅសាធារណៈប្រជាមានិតឡាវ ១២ នាក់បានទៅប្រទេសប៉ូឡូញ ៧៦៩ នាក់បានទៅប្រទេសរុស្ស៊ី ៣៤ នាក់បានទៅប្រទេសថៃ ៣០ នាក់បានទៅប្រទេសអាមេរិច និង៧៩៧ នាក់បានទៅសិក្សានៅប្រទេសវៀតណាម (Virak, 2009)។ ជារួម ការអភិវឌ្ឍ ការអប់រំថ្នាក់ឧត្តមសិក្សានៅ កម្ពុជានៅក្នុងកំឡុងពេលនោះបានប្រឈមបញ្ហាជាច្រើនក្នុងការផ្តល់សេវាអប់រំ ដោយសារតែអស្ថេរភាពនយោបាយ និងសង្គ្រាមស៊ីវិល។

### ២.១.៤. សម័យសម្តេចនាយករដ្ឋមន្ត្រីតេជោ ហ៊ុន សែន (១៩៩៨ - ២០១៣)

បន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ រដ្ឋាភិបាលថ្មីត្រូវបានប្រកាសដឹកនាំដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងឆ្នាំ ១៩៩៨។ លោក ហ៊ុន សែន បានគ្រប់គ្រងប្រទេសជានាយករដ្ឋមន្ត្រីប្រទេសកម្ពុជាអស់រយៈពេលបីអណត្តិនៅក្នុងឆ្នាំ ១៩៩៨-២០០៣ ឆ្នាំ ២០០៣-២០០៨ និងឆ្នាំ

២០០៨-២០១២។ ទន្ទឹមគ្នានេះដែរ ការអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជាត្រូវបានអ្នកជំនាញខាងអប់រំជាច្រើននាក់យល់ឃើញថា វាស្ថិតនៅក្នុងចំនុចគួរព្រួយបារម្ភ និងនៅក្នុងស្ថានភាពលំបាកមួយដោយសារតែ គ្រឹះស្ថានអប់រំឧត្តមសិក្សាភាគច្រើនចាប់ផ្តើមដំណើរការរបស់ខ្លួនជាមួយធនធានហិរញ្ញវត្ថុមានដែនកំណត់ ហើយម្យ៉ាងទៀតគ្រឹះស្ថានទាំងនោះមានការពាក់ព័ន្ធនឹងនយោបាយដោយគ្មានតម្លាភាពនៅក្នុងជ្រើសរើសសិក្សា (Ford, 2006)។ នៅពេលនោះ មានស្ថាប័នអប់រំកម្រិតឧត្តមសិក្សាចំនួន ៩១ស្ថាប័ន ដែលមាន៣៤ ជាស្ថាប័នរដ្ឋ និង ៥៧ ជាសាកលវិទ្យាល័យឯកជនដែលស្ថិតនៅតាមខេត្តទាំង១៩ និងនៅទីក្រុងភ្នំពេញ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ ការរីកដុះដាលនៃស្ថាប័នអប់រំកម្រិតឧត្តមសិក្សា គឺបានបង្ហាញពីការកើនឡើងនៃចំនួនអ្នកចុះឈ្មោះចូលរៀន។ យោងតាមរបាយការណ៍របស់ក្រសួងអប់រំ អត្រានៃការចុះឈ្មោះប្រចាំឆ្នាំសរុបបានកើនឡើងយ៉ាងខ្លាំងរហូតដល់ទៅបួនដងពី ៤១,០០០នាក់ ទៅដល់ ១៧៣,០០០ ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០១០ ដែលក្នុងនោះប្រហែលជា ៩១% គឺជានិស្សិតសិក្សាបង់ថ្លៃនៅក្នុងសាលារដ្ឋ និងឯកជន។ ជាពិសេសនៅក្នុងឆ្នាំសិក្សា ២០១០-២០១១ មាននិស្សិតថ្នាក់បណ្ឌិតចំនួន ៩៨១នាក់ និស្សិតថ្នាក់អនុបណ្ឌិតចំនួន ១២,៨៨៧នាក់ និស្សិតបរិញ្ញាបត្រចំនួន ១៧៣,២៦៤នាក់ និងនិស្សិតបរិញ្ញាបត្ររងចំនួន ២០,៧១៩នាក់ (MoEYS, 2011)។ ដោយសារតែការកើនឡើង ចំនួនគ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សា និងអ្នកចុះឈ្មោះចូលរៀន អ្នកប្រាជ្ញជាច្រើន បានបកស្រាយទិដ្ឋភាពអប់រំថ្នាក់ឧត្តមសិក្សានៅកម្ពុជា ថាជាការឆ្លងកាត់បដិវត្តន៍ស្ងៀមស្ងាត់មួយ (Rockefeller Foundation Supported Project, 2006)។ សាកលវិទ្យាល័យឯកជនជាច្រើនបានរីកដុះដាលឡើង ដើម្បីផ្តល់សេវាកម្មអប់រំទូទាំងប្រទេស។

## ២.២. គោលនយោបាយអប់រំទូទៅ ២០១៤-២០១៨

### ២.២.១. ការពង្រឹងគុណភាពវិស័យអប់រំ

ការពង្រឹងគុណភាពសេវាអប់រំ គឺជាអាទិភាពចម្បងមួយរបស់រាជរដ្ឋាភិបាលកម្ពុជានិងជាគន្លឹះចាំបាច់នៃការចូលរួមក្នុងកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍធនធានមនុស្ស។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនិងអនុវត្តនូវអភិក្រមគ្រប់គ្រងទូទាំងវិស័យ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣។ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣ បានចូលរួមចំណែកបង្កើនការចូលរៀនរបស់កុមារកម្ពុជា ប្រកបដោយសមធម៌ក្នុងការផ្តល់ឱកាសសិក្សារៀនសូត្រ ជាពិសេសក្នុងកម្រិតបឋមសិក្សា ដើម្បីឲ្យកុមារក្លាយជាពលរដ្ឋមានចំណេះដឹងនិង

សកម្ម ដែលនឹងក្លាយទៅជាកម្លាំងស្នូលដ៏សំខាន់សម្រាប់ការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចកម្ពុជា។

រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងក្នុងការបង្កើនថវិការបស់ខ្លួន និងកៀងគរជំនួយកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពីដៃគូអភិវឌ្ឍនានា សម្រាប់អនុវត្តកំណែទម្រង់វិស័យអប់រំ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៩-២០១៣ សំដៅសម្រេចបានគោលនយោបាយជាអាទិភាពសំខាន់ៗ ដើម្បីរួមចំណែកដល់ការកសាង និងការអភិវឌ្ឍធនធានមនុស្សរបស់ព្រះរាជាណាចក្រកម្ពុជា។ គោលនយោបាយជាអាទិភាពសំខាន់ៗរួមមាន៖

- ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ដោយខិតខំកសាងសាលារៀនឲ្យកាន់តែជិតលំនៅឋានរបស់ប្រជាពលរដ្ឋ បង្កើតអន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិត ពិសេសសម្រាប់សិស្ស និស្សិតជានារីភេទ ផ្គត់ផ្គង់ថវិកាដំណើរការគ្រឹះស្ថានសិក្សាផ្តល់គ្រូបង្រៀនប្រកបដោយគុណភាព។
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ តាមរយៈការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សា បណ្ណាល័យ និងបន្ទប់ពិសោធន៍ ការជំរុញកំណែទម្រង់កម្មវិធីសិក្សា និងការបង្កើនម៉ោងសិក្សា ព្រមទាំងខិតខំផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រឲ្យបានច្រើន។
- អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីដោយជំរុញការកែលម្អរចនាសម្ព័ន្ធការងារកសាងច្បាប់និងលិខិតបទដ្ឋានឲ្យបានគ្រប់គ្រាន់ ជាមួយនោះ ធ្វើការបណ្តុះបណ្តាលបច្ចេកទេសជំនាញដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ផ្នែកអប់រំឧត្តមសិក្សាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ដោយគ្រឹះស្ថានឧត្តមសិក្សាមានចំនួន១០១ ក្នុងនោះគ្រឹះស្ថានរដ្ឋមានចំនួន៣៩ និងគ្រឹះស្ថានឯកជនមានចំនួន៦២។ និស្សិតដែលបានបញ្ចប់ការសិក្សាចាប់ពីបរិញ្ញាបត្ររងដល់ថ្នាក់បណ្ឌិតមានចំនួន៩៥ ៦៥០នាក់។ ប៉ុន្តែការអនុវត្តប្រព័ន្ធធានាគុណភាព នៅពុំទាន់បានពេញលេញព្រមទាំងចំនួនគ្រឹះស្ថាននៅកម្រិតឧត្តមសិក្សាដែលមានគុណភាពនិងភាពឆ្លើយតប នៅមានចំនួនតិចតួចប៉ុណ្ណោះ។

### ២.២.២ បញ្ហាប្រឈម និងដំណោះស្រាយក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០០៩-២០១៣)

ខាងក្រោមនេះគឺជាបញ្ហាប្រឈមដែលកើតមាន រួមទាំងដំណោះស្រាយដែលត្រូវបានអនុវត្តអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣។

- **បញ្ហា៖** គុណភាពនិងភាពឆ្លើយតបរបស់ការសិក្សានៅមានកម្រិត

  **ដំណោះស្រាយ៖** ការបង្កើតក្របខ័ណ្ឌធានាគុណភាពនៅថ្នាក់ជាតិ ដែលអាចវាស់វែងបានពីលទ្ធផលនៃការសិក្សារបស់សិស្ស។ ការពង្រឹងការធ្វើតេស្តតាមថ្នាក់រៀនជាប្រចាំ និងការវាយតម្លៃការសិក្សា។ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតប តាមរយៈការពិនិត្យឡើងវិញកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល។

- **បញ្ហា៖** ការបង្កើនការចូលរៀននិងគុណភាពនៅឧត្តមសិក្សា

  **ដំណោះស្រាយ៖** ការរៀបចំចក្ខុវិស័យសម្រាប់ឧត្តមសិក្សា និងការផ្តោតលើកម្មវិធីអាទិភាព (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា) ស្របជាមួយស្តង់ដាធានាគុណភាពរបស់អាស៊ាន។

- **បញ្ហា៖** ការផ្គត់ផ្គង់និងការពង្រាយគ្រូមានគុណភាព

  **ដំណោះស្រាយ៖** ការពង្រាយគ្រូបង្រៀននៅតាមវិទ្យាល័យនិងអនុវិទ្យាល័យដែលបង្កើតថ្មីពិសេសតំបន់ជួបការលំបាក។ ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនលើមុខវិជ្ជាគណិតវិទ្យាវិទ្យាសាស្ត្រ តាមរយៈការងារវិក្រឹត្យការគ្រូបង្រៀននិងការដាក់ឲ្យអនុវត្តប្រព័ន្ធការវាយតម្លៃគុណភាព។

- **បញ្ហា៖** ការផ្គត់ផ្គង់សៀវភៅសិក្សាគោល

  **ដំណោះស្រាយ៖** ការពិនិត្យឡើងវិញនិងការកែលម្អប្រព័ន្ធបែងចែកនិងគ្រប់គ្រងសៀវភៅសិក្សាគោល។ ការធានាថាការផ្គត់ផ្គង់សៀវភៅសិក្សាគោល កម្មវិធីសិក្សាថ្មី និងការផ្តល់សៀវភៅគ្រូដល់គ្រូបង្រៀននៅតំបន់ជួបការលំបាក។

- **បញ្ហា៖** ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ និងការត្រៀមអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការ

  **ដំណោះស្រាយ៖** ការអភិវឌ្ឍសមត្ថភាពរបស់នាយកសាលា មន្ត្រីគ្រប់គ្រងនៅថ្នាក់ មន្ទីរនិងការិយាល័យអប់រំ យុវជន និងកីឡាស្រុក។ ការពង្រឹងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ក្នុងការពិនិត្យតាមដាន និងគាំទ្រសាលារៀនគ្រប់កម្រិត។

- **បញ្ហា៖** ការអភិវឌ្ឍជំនាញបច្ចេកទេសដល់យុវជន

  **ដំណោះស្រាយ៖** ការបង្កើនអត្រាចូលរៀន ស្តីពីបច្ចេកទេសអប់រំ បច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និងបានរៀបចំខ្លួនជាស្រេចសម្រាប់ធ្វើសមាហរណកម្មក្នុងតំបន់ក្នុងឆ្នាំ២០១៥សម្រាប់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្មនិងកំណើនកាលានុវត្តភាពការងារ។

- **បញ្ហា៖** ការពង្រឹងសកម្មភាពយុវជននិងកីឡា

**ដំណោះស្រាយ៖** ការជម្រុញសកម្មភាពអប់រំកាយនិងកីឡានៅតាមសាលារៀន និងសកម្មភាពសមាគមកីឡា ក្លឹបកីឡា និងការកសាងហេដ្ឋារចនាសម្ព័ន្ធ។

### ២.២.៣. ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស

ដើម្បីលើកកម្ពស់វិស័យអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការបណ្តុះបណ្តាលបច្ចេកទេស រដ្ឋាភិបាលបានអនុវត្តគោលនយោបាយដូចខាងក្រោម៖

- ការបញ្ជ្រាបការយល់ដឹងអំពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងផលប្រយោជន៍នៃការប្រើប្រាស់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ពិសេសកម្រិតមធ្យមសិក្សាទុតិយភូមិ កម្រិតបណ្តុះបណ្តាលបច្ចេកទេស និងនៅកម្រិតឧត្តមសិក្សា។
- ការជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍ រួមទាំងការបង្កើតបណ្តាញស្រាវជ្រាវគំរូរវាងសាកលវិទ្យាល័យ ភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាលនិងសហគ្រាស។
- ការបន្តអភិវឌ្ឍស្ថាប័ននិងសមត្ថភាពរបស់មន្ត្រីអប់រំ តាមរយៈការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និងការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធការពង្រឹងរចនាសម្ព័ន្ធការងារ និងការបណ្តុះបណ្តាលជំនាញដល់មន្ត្រី។
- ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សា និងក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញទាំងក្នុងគ្រឹះស្ថានរដ្ឋ និងគ្រឹះស្ថានឯកជនឲ្យស្របទៅតាមកម្រិតស្តង់ដាអន្តរជាតិ និងតម្រូការអភិវឌ្ឍរបស់ប្រទេសតាមរយៈការពង្រឹងការបណ្តុះបណ្តាល និងរិត្រឹតការគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការធ្វើអធិការកិច្ច និងការពង្រឹងសមត្ថភាពគ្រប់គ្រង ការលើកទឹកចិត្តគ្រូបង្រៀនក្នុងការបង្កើនសមត្ថភាពបង្រៀន ការពង្រឹងគុណភាពក្នុងការប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ការលើកកម្ពស់ការសិក្សាភាសាបរទេសដែលចាំបាច់ការកែលម្អលក្ខខណ្ឌនៃការសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍ និងការបង្កើនការផ្គង់ផ្គង់សម្ភារៈសិក្សាព្រមទាំងការចូលរួមរបស់មាតាបិតាអាណាព្យាបាលនិងសហគមន៍។
- ការជំរុញការរៀបចំ និងការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សំដៅលើកកម្ពស់ផលិតភាពការងាររបស់ពលករ ដោះស្រាយនិងកាត់បន្ថយភាពគ្មានការងារធ្វើរបស់យុវជន ព្រមទាំងបង្កើនចំណូលរបស់ប្រជាជននិងធានាសមធម៌។

- ការបន្តពង្រឹងគុណភាពនៃការអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការអភិវឌ្ឍ សម្រាប់យុវជននូវជំនាញបច្ចេកទេសនិងជំនាញទន់ ពិសេស ការធ្វើការងារជាក្រុម ការគោរពវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងកន្លែងការងារ តាមរយៈការកែលម្អកម្មវិធីបណ្តុះបណ្តាល ការពង្រឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ការបង្កើតស្តង់ដាជាតិ សមត្ថភាព ការត្រួតពិនិត្យ និងការធ្វើតេស្តសមត្ថភាព ការទទួលស្គាល់មុខជំនាញ និងការប្រកួតប្រជែងជំនាញ សំដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការទីផ្សារពលកម្ម បង្កើនកាលានុវត្តភាពទទួលបានការងារ និងប្រើប្រាស់ឲ្យអស់សមត្ថភាពនូវផលលាភប្រជាសាស្ត្ររបស់កម្ពុជា ក៏ដូចជាដើម្បីបង្កើតលក្ខខណ្ឌសមស្រប សម្រាប់ពលករកម្ពុជាអាចឈានឡើងទៅកាន់តួនាទីគ្រប់គ្រង និងដឹកនាំ។

លើសពីនេះរដ្ឋាភិបាលក៏មានបំណងលើកកម្ពស់គុណភាពនិងភាពឆ្លើយតប តាមរយៈការធ្វើឲ្យកុមារនិងយុវជនគ្រប់រូបទទួលបានការអប់រំដែលមានគុណភាព និងភាពឆ្លើយតប ដែលអាចឲ្យពួកគេចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយសក្តិសិទ្ធិ។ កុមារនិងយុវជន និងទទួលបានជំនាញក្នុងការគំនិត និងពិចារណា និងមានមូលដ្ឋានរឹងមាំលើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ ភាសាបរទេស សង្គម និងបំណិនជីវិត។ ដើម្បីសម្រេចគោលបំណងនៃគោលនយោបាយនេះ ក្រសួងនឹងអនុវត្តដូចខាងក្រោមៈ

- ធ្វើកំណែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេសឲ្យស្របនឹងបទពិសោធន៍ល្អៗរបស់អន្តរជាតិ។
- កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព រួមជាមួយនឹងការផ្តល់គ្រូបង្រៀនដែលបានបណ្តុះបណ្តាលនិងមានគុណភាពគ្រប់គ្រាន់ នៅគ្រប់កម្រិតសិក្សានិងផ្តល់សៀវភៅសិក្សាគោល ព្រមទាំងសម្ភារៈសិក្សានានា។
- កម្មវិធីពង្រឹងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិនិងអន្តរជាតិ ពង្រឹងការធ្វើតេស្តថ្នាក់រៀនជាប្រចាំនិងការវាយតម្លៃថ្នាក់ជាតិ ការកែទម្រង់ការប្រឡងថ្នាក់ជាតិ និងការត្រៀមខ្លួនចូលរួមក្នុងកម្មវិធីវាយតម្លៃការសិក្សារបស់សិស្សថ្នាក់អន្តរជាតិ។
- កម្មវិធីអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ អនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិថ្នាក់ជាតិ ដើម្បីបង្កើនគុណភាពនៃការអប់រំបច្ចេទេសនិងវិជ្ជាជីវៈ និងរៀបចំស្ថាប័នសម្របសម្រួល ជាមួយនឹងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការផ្តល់កាលានុវត្តភាពសិក្សាផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ។

- កម្មវិធីគ្រប់គ្រងនិងវាយតម្លៃការបំពេញការងាររបស់បុគ្គលិក សម្រាប់បង្កើនគុណភាពនៃការបង្រៀន ការវាយតម្លៃ ការសរសើរ ការលើកទឹកចិត្ត និងការបន្តការអភិវឌ្ឍវិជ្ជាជីវៈ ជាពិសេស តាមរយៈយន្តការសម្រាប់ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន។
- កម្មវិធីអភិវឌ្ឍឧត្តមសិក្សា កែទម្រង់ប្រព័ន្ធអប់រំនៅឧត្តមសិក្សាឲ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីស្របជាមួយនឹងស្តង់ដាក្នុងតំបន់និងអន្តរជាតិ លើកកម្ពស់គុណភាពនៃដំណើរការរបស់ប្រព័ន្ធ តាមរយៈការតម្រូវឲ្យគ្រឹះស្ថានឧត្តមសិក្សាទាំងអស់គោរពតាមស្តង់ដាអប្បបរមា ផ្តោតជាសំខាន់លើការបង្រៀននិងស្រាវជ្រាវលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា ការបង្កើនចំនួនគ្រូបង្រៀននិងសាស្ត្រាចារ្យដែលមានគុណ-ភាព (សញ្ញាបត្រ បរញ្ញបត្រជាន់ខ្ពស់និងបណ្ឌិត)។ ការពិនិត្យឡើងវិញនិងចេញសេចក្តីណែនាំស្តីពីការកំណត់តម្លៃសិក្សា ការបង្កើនអាហារូបករណ៍ដល់សិស្ស និស្សិតពូកែតាមមុខវិជ្ជាដែលស្របនឹងតម្រូវការទីផ្សារការងារ គម្រោងកម្ចីសិក្សា និងគម្រោងសម្រាប់ធានាការលើកទឹកចិត្តគ្រប់គ្រាន់ ដល់បុគ្គលិកដែលមានគុណវឌ្ឍិខ្ពស់ និងបុគ្គលិកធម្មតា។
- ការរៀបចំចក្ខុវិស័យសម្រាប់ឧត្តមសិក្សា និងការផ្តោតលើកម្មវិធីអាទិភាព (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា) ស្របជាមួយស្តង់ដាធានាគុណភាពរបស់អាស៊ាន។

## ២.៣. ការអប់រំ STEM នៅប្រទេសកម្ពុជា

### ២.៣.១. ទិដ្ឋភាពរួមអំពីការអប់រំ STEM នៅប្រទេសកម្ពុជា

យោងតាមប្រភព The international journal of Stem Education STEM សំដៅលើការអប់រំដែលផ្តោតលើការបង្រៀន និងការសិក្សាពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ បច្ចុប្បន្ននេះ គម្លាតនៃជំនាញដែលនិស្សិតកម្ពុជាបានសិក្សា និងជំនាញដែលគេត្រូវការនៅក្នុងទីផ្សារបានស្តែងចេញកាន់តែច្បាស់ ដោយសារការសិក្សាបែបប្រពៃណី ឬការសិក្សាមិនទាន់សម័យ ទទួលបរាជ័យនៅក្នុងការបណ្តុះបណ្តាលនិស្សិតនូវជំនាញដែលពួកគេត្រូវការ ដើម្បីស្វែងរកអាជីពចិញ្ចឹមជីវិត (Kaing, 2016)។ តាមប្រភពដែល តម្រូវការកំលាំងពលកម្មដែលមានជំនាញច្បាស់លាស់បាននឹងកំពុងកើនឡើងក្នុងប្រមាណឆ្នាំចុងក្រោយនេះ ដោយសារប្រទេសកម្ពុជាបានផ្លាស់ប្តូរពី វិស័យកសិកម្មឆ្ពោះទៅរកវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម។ ដូច្នេះ ការលើកកម្ពស់ការអប់រំ STEM គឺពិតជាមានសារៈសំខាន់ និងចាំបាច់បំផុតសម្រាប់ប្រទេសកម្ពុជា ដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងជាលក្ខណៈអន្តរជាតិនាពេលខាងមុខ។ យោងតាមរបាយការណ៍របស់វិទ្យាស្ថានស្រាវជ្រាវដើម្បីការអភិវឌ្ឍនៅកម្ពុជា (CDRI) ២០១៤ និស្សិតដែលបានបញ្ចប់ការ

សិក្សាថ្នាក់ មហាវិទ្យាល័យលើជំនាញ ធុរៈកិច្ច ហិរញ្ញវត្ថុ និង ភាសាបរទេស និងមនុស្សសាស្ត្រ មានជាង ៧០% ខណៈពេលដែល និស្សិតដែលបានបញ្ចប់ការសិក្សាលើជំនាញ STEM មានតិចជាង ២០% (Parikh, 2016)។

ផ្អែកលើការលើកឡើងរបស់ ឯកឧត្តម William Longhurst ដែលជាអគ្គរាជទូតអង់គ្លេស បានគូសបញ្ជាក់ថា អាជីពខាងផ្នែក វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) គឺមានតម្រូវការខ្ពស់បំផុតនៅក្នុងពិភពលោក រាប់បញ្ចូលទាំងនៅប្រទេសកម្ពុជាផងដែរ។ ស្រដៀងគ្នានេះដែរ ការសិក្សាលើ STEM នឹងទទួលបានជោគជ័យខ្លាំងបំផុត ដោយសារក្រុមហ៊ុនជាច្រើនត្រូវការកាន់តែខ្លាំងឡើងនូវធនធានមនុស្ស ដែលអាចសម្របទៅនឹងបដិវត្តន៍ឧស្សាហកម្មជំណាក់កាលទី៤ នេះ (Armbrecht, 2016)។ ប្រភពដដែលបានបន្តទៀតថា យុវជនកម្ពុជាត្រូវតែយល់ឱ្យច្បាស់ពីឱកាសការងារ និងជំនាញដែលត្រូវនឹងការងារនីមួយៗ ដើម្បីសម្របទៅតាមការអភិវឌ្ឍសេដ្ឋកិច្ច និងការបើកចំហរទៅរកវិនិយោគិនបរទេស។ ផ្ទុយទៅវិញ ដោយផ្អែកលើប្រភពដដែល ប្រទេសកម្ពុជាកំពុងប្រឈមមុខទៅនឹងការខ្វះខាតធនធានមនុស្សដែលបានជំនាញវិជ្ជាជីវៈខាង STEM ដោយសារពួកគេគិតថា មុខវិជ្ជាទាក់ទងនឹង STEM គឺពិបាកខ្លាំងក្នុងការរៀនសូត្រ ហើយពួកគេដឹងច្បាស់ថា

នឹងមិនអាចរកការងារល្អបានបន្ទាប់ពីបញ្ចប់ការសិក្សា។ ប៉ុន្តែ កម្ពុជាពិតជាត្រូវការអ្នកមានជំនាញខាងស្ថិតិ វិស្វកម្ម អ្នកអភិវឌ្ឍន៍បណ្តាញ និងវេជ្ជបណ្ឌិតជាច្រើន ដើម្បីអភិវឌ្ឍប្រទេស និងសេដ្ឋកិច្ចរបស់ខ្លួន (Blanquat & Associates , 2016)។

### ២.៣.២. សារៈសំខាន់នៃការអប់រំ STEM

ការអប់រំ STEM គឺជាប្រធានបទថ្មីមួយដែលគេកំពុងពិភាក្សាក្នុងចំណោមអ្នកបង្កើតគោលនយោបាយ និងភាគីពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ និងស្ថាប័នបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ។ ការអប់រំពី STEM ត្រូវបានគេបន្លឺឡើង ដើម្បីបង្កើនលទ្ធភាពផលិតកម្មនៅកម្ពុជា ដើម្បីបង្កើនខ្សែចង្វាក់ផលិតកម្មក៏ដូចជាដើម្បីបង្កើនប្រាក់ខែ និងការលើកកម្ពស់ជីវភាពរស់នៅជាដើម (Holman, 2015)។ ស្រដៀងគ្នានេះដែរ រដ្ឋមន្ត្រីក្រសួងអប់រំក៏បានថ្លែងនៅក្នុងព្រឹត្តិការណ៍ STEM (Stem Festival) ថា កម្ពុជាត្រូវការយុវជនដែលមានជំនាញ និងមានសមត្ថភាពខាងផ្នែក STEM ជាច្រើននាក់ ដើម្បីអភិវឌ្ឍធនធានមនុស្ស សេដ្ឋកិច្ច និងជម្រុញការអភិវឌ្ឍជាតិ និងដើម្បីប្រកួតប្រជែងទាំងក្នុងតំបន់ និងក្នុងសាកលលោក (Mark, 2016)។ លើសពីនេះទៅទៀត ពួកគេទាំងនោះគឺជាឆ្អឹងខ្នងរបស់សង្គមដែលមានការអភិវឌ្ឍ និងជាចលករវុញច្រានសេដ្ឋកិច្ចនៅក្នុងប្រទេស (Walter,

2013) ។ មួយវិញទៀត ជំនាញ STEM គឺពិតជាសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចប្រទេសកម្ពុជា ដើម្បីផ្លាស់ប្តូរទៅរកឧស្សាហកម្មដែលបង្កើតតម្លៃបន្ថែម និងការច្នៃប្រឌិត។ យ៉ាងណាក៏ដោយ ការខ្វះខាតអ្នកជំនាញខាងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៅក្នុងប្រទេសកម្ពុជា នៅតែជាឧបសគ្គក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជាឲ្យរួចផុតពីកសិកម្មនិងផលិតកម្ម ឆ្ពោះទៅរកការរកកម្រៃឲ្យបានកាន់តែច្រើន ការស្រាវជ្រាវដែលមានលក្ខណៈប្រកួតប្រជែង និងការអភិវឌ្ឍ (Parikh, 2016)។

ភស្តុតាងដ៏ច្បាស់ក្រឡែតមួយគឺនៅត្រង់ថា ឥរិយាបថនៃការព្រងើយកន្តើយចំពោះការអប់រំអំពី STEM បានផ្លាស់ប្តូរយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់តាមរយៈការបើកកម្មវិធីមហោស្រពវិទ្យាសាស្ត្រ និងវិស្វកម្ម នៅទីក្រុងភ្នំពេញ ក្នុងខែ មីនា ឆ្នាំ ២០១៦ ដែលមានមនុស្សចំនួនជាង ១០,០០០នាក់បានចូលរួមក្នុងរយៈពេលទាំងបីថ្ងៃ ដែលច្រើនជាងការរំពឹងទុកដែលដល់ទៅ ៣,០០០នាក់ (Mark, 2016) ។ គោលបំណងនៃព្រឹត្តិការណ៍នោះគឺដើម្បីផ្លាស់ប្តូរផ្នត់គំនិតរបស់មនុស្សទៅលើ STEM និងលើកទឹកចិត្តនិស្សិតឲ្យគិតអំពី STEM ធ្វើជាអាជីពទៅថ្ងៃអនាគត។

### ២.៣.៣. យុទ្ធសាស្ត្រក្នុងការជំរុញ STEM នៅប្រទេសកម្ពុជា

រដ្ឋមន្ត្រីក្រសួងអប់រំថ្មីរបស់ក្រសួងអប់រំ លោកបណ្ឌិត ហង់ ជួនណារ៉ុង និងអគ្គរាជទូតអង់គ្លេសនៅទីក្រុងភ្នំពេញបានខិតខំយ៉ាងខ្លាំងក្នុងការជម្រុញការយល់ដឹងអំពី STEM តាមរយៈការបង្កើតព្រឹត្តិការណ៍ STEM។ ក្រោមគំនិតផ្តួចផ្តើមពីក្រសួងអប់រំ (MOEYS) និងអគ្គរាជទូតអង់គ្លេស បណ្តាញនៃអ្នកស្ម័គ្រចិត្តដែលបានធ្វើការនៅក្នុងអាជីពទាក់ទងនឹង STEM នឹងធ្វើដំណើរទូទាំងប្រទេស ដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេ ដើរតួជាជនគំរូ និងជាអ្នកណែនាំដល់យុវជនជំនាន់ក្រោយ (Mark, 2016) ។ លើសពីនេះទៅទៀត ស្ថាប័នក្នុងតំបន់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពាក់បំប៉នយុវជនទៅក្នុងអាជីព STEM ផងដែរ។ ឧទាហរណ៍ The Golden West Design Lab បានផ្តល់ឱកាសការងារយកកំរៃដល់និស្សិតថ្នាក់បរិញ្ញាបត្រវិស្វកម្ម ខណៈពេលដែលពួកគេនៅជានិស្សិតកំពុងសិក្សានៅឡើយ (Anonymous, 2015)។ លើសពីនេះទៅទៀត រដ្ឋមន្ត្រីក្រសួងអប់រំ បានកំណត់ផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ ដើម្បីបណ្តុះបណ្តាលគ្រូលើជំនាញគណិតវិទ្យា ជំនាញពិសោធន៍ និងវិទ្យាសាស្ត្រ ដើម្បីពង្រឹងការអប់រំ STEM ទាំងនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ហើយធ្វើយ៉ាងណាឲ្យការបង្រៀនមានភាពទាក់ទាញ (Parikh, 2016)។ បន្ថែមលើនេះ ក្លឹបសិក្សាអំពី STEM ការរៀបចំព្រឹត្តិការណ៍វិទ្យាសាស្ត្រ ការផ្តល់ជូនឧបករណ៍សម្រាប់ការសិក្សានៅលើប្រពន្ធ័អ៊ីនធឺណែតត្រូវតែជំរុញលើកទឹកចិត្ត ដើម្បីនាំមកនូវកម្មវិធីសិក្សា វិធីសាស្ត្រនៃការបង្រៀន និងធនធានសិក្សា ដែលមានលក្ខណៈសមស្របទៅនឹងស្តង់

ជាអន្តរជាតិ។ បន្ទាប់មកទៀត វិស័យធុរៈកិច្ចអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឱកាសចុះកម្មសិក្សាដល់និស្សិត ដើម្បីអនុញ្ញាតឲ្យពួកគេទទួលបានការអនុវត្ត និងបទពិសោធន៍ការងារជាក់ស្តែង។ លើសពីនេះទៅទៀត កម្មវិធី ដែលចុះទៅតាមខេត្តទូទាំងប្រទេស ដោយមានការរៀបចំពិធីតាំងពិពណ៌អំពីវិទ្យាសាស្ត្រ និងវិស្វករសម្រាប់យុវសិស្សនៅតាមបណ្តាខេត្ត គឺជាផែនការមួយផ្សេងទៀត ដើម្បីបន្តជំរុញឲ្យមានការចូលរួមជាមួយអាជីព STEM នេះ។ គោលបំណងរួមរបស់ក្រសួងអប់រំគឺដើម្បីជំរុញការអប់រំ STEM ឲ្យមានភាពពេញនិយម និងមានមនុស្សកាន់តែច្រើនផ្តោតអារម្មណ៍លើការសិក្សា STEM ជាអាជីពទៅថ្ងៃអនាគត (Anonymous, 2015) ។ ម្យ៉ាងវិញទៀត Walter ក៏បានស្នើដល់ក្រសួងអប់រំថា ក្រសួងអប់រំ យុវជន និងកីឡា គួរតែរៀនសូត្រ និងធ្វើការទំនាក់ទំនងជាមួយក្រសួងអប់រំប្រទេសសិង្ហបុរី ដើម្បីមើលពីរបៀបរបប និងមូលហេតុដែលធ្វើឲ្យប្រទេសនេះ ជានិច្ចកាលជាប្រទេសឈានមុខលេខរៀងទីពី ឬទីបី ក្នុងចំណោមប្រទេសជាច្រើនទៀតលើសាកលលោកក្នុងការអប់រំផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា (Walter, 2013)។ ប្រភពដដែលបានបន្ថែមទៀត វាជាគំនិតល្អមួយប្រសិនបើក្រសួងអាចផ្តល់ការលើកទឹកចិត្ត និងអត្ថប្រយោជន៍ សមរម្យទៅដល់ក្រុមការងារនៅតាមសាកលវិទ្យាល័យ និងនិស្សិតដែលមិនសូវមានការចាប់អារម្មណ៍លើ STEM ដែលក្នុងនោះមានដូចជា មូលនិធិដែលត្រូវបានផ្តល់ដោយផ្ទាល់ទៅតាមសាកលវិទ្យាល័យទាំងឡាយណាដែលមានឆន្ទៈក្នុងការវិនិយោគលើជំនាញ STEM។ លើសពីនោះ ក្រសួងអាចផ្តល់ការគាំទ្រផ្សេងៗទៀតដូចជា ការកសាងសមត្ថភាពមន្ត្រីអប់រំ និងមន្ត្រីជំនាញការបង្កើតគម្រោងស្រាវជ្រាវ និងការឧបត្ថម្ភឧបករណ៍ពិសោធន៍ជាដើម។ ដំណោះស្រាយដ៏ប្រសើរមួយ គឺការផ្តល់អាហារូបករណ៍ទាំងស្រុងដល់និស្សិត ដែលចង់សិក្សាជំនាញវិស្វកម្ម និងជំនាញដ៏ទៃទៀតដែលមានលក្ខណៈស្រដៀង STEM (Kung, 2014)។

សរុបជារួម ការអប់រំ STEM នៅប្រទេសកម្ពុជាមិនទាន់មានលក្ខណៈរឹងមាំនៅឡើយទេ ដោយសារកង្វះខាតការយល់ដឹងពីសារៈសំខាន់នៃមុខវិជ្ជា STEM ពីសំណាក់ប្អូនៗសិស្សានុស្សិត។ ជាលទ្ធផល ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំសហការហ៍ជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីបង្កើតជាសិក្ខាសាលា និងការតាំងពិព័រណ៍ពី STEM ជាច្រើននាពេលកន្លងមក ដើម្បីលើកកម្ពស់ការយល់ពីមុខវិជ្ជា STEM ក៏ដូចជាដើម្បីកសាងធនធានមនុស្សបន្ថែមលើជំនាញទាក់ទងនឹង STEM។

# ជំពូកទី ៣
# ការវិភាគទិន្នន័យ

## ៣.១. ការវិភាគ និងបកស្រាយអត្ថន័យអថេរឯករាជ្យទាំងបួន

ដើម្បីរកឲ្យឃើញពីឥទ្ធិពលនៃការសិក្សាពីរជំនាញលើលទ្ធផលសិក្សារបស់និស្សិត យើងនឹងប្រើអថេរឯករាជ្យចំនួនបួនដែលមានឥទ្ធិពលខ្លាំង ទៅលើលទ្ធផលសិក្សាឬមធ្យមភាគនៃការសិក្សារបស់និស្សិត (GPA)។ អថេរទាំងបួននោះគឺ ការចូលរួមក្នុងថ្នាក់ ចំណង់នៃការសិក្សា ការគ្រប់គ្រងពេលវេលា និងសុខភាពរបស់និស្សិត។

យោងតាមលទ្ធផលនៃកម្រងសំណួរដែលទទួលបានពីនិស្សិតសិក្សាពីរជំនាញទាំង៦០នាក់ យើងទទួលបានលទ្ធផលនៃការវិភាគទិន្នន័យដូចខាងក្រោម៖

**ក្រាហ្វិក ៣.១៖ បង្ហាញពីកត្តាដែលជំរុញឲ្យនិស្សិតសិក្សាពីរជំនាញក្នុងពេលតែមួយ**



- កត្តាដែលមានឥទ្ធិពលខ្លាំងជាងគេក្នុងការជំរុញឲ្យនិស្សិតសម្រេចចិត្តសិក្សាពីរជំនាញ គឺ កត្តាឱកាសការងារ (៥០%) និងបន្ទាប់មកគឺកត្តាខ្លួនឯង (២៦.៧០%)។ នេះមានន័យថា និស្សិតភាគច្រើនជ្រើសរើសការសិក្សាពីរជំនាញដោយសារ ពួកគេសង្ឃឹមថា នឹងទទួលបានឱកាសការងារច្រើនជាមួយនឹងប្រាក់កំរៃខ្ពស់។

**ក្រាហ្វិក ៣.២៖ បង្ហាញពីឥទ្ធិពលនៃការសិក្សាពីរជំនាញលើការចូលរួមក្នុងថ្នាក់របស់និស្សិត**




- ចំពោះការចូលរួមក្នុងថ្នាក់ បញ្ហាដែលនិស្សិតជួបប្រទះញឹកញាប់ជាងគេ គឺ បញ្ហាការធ្វើកិច្ចការស្រាវជ្រាវនិងបទបង្ហាញ (៧០%) ដែលបញ្ហាទាំងនោះរួមមាន ពួកគេគ្មានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការងារទាំងនោះឲ្យបានល្អនិងទាន់ពេលវេលា ហើយពេលខ្លះពួកគេមិនបានយល់ច្បាស់ពីមេរៀនដែលទាក់ទងនឹងកិច្ចការស្រាវជ្រាវនោះ ដែលធ្វើឲ្យទទួលបានលទ្ធផលមិនសូវល្អ។

## ក្រាហ្វិក ៣.៣៖ បង្ហាញពីឥទ្ធិពលនៃការសិក្សាពីរជំនាញលើចំណង់នៃការសិក្សារបស់និស្សិត




- ទាក់ទងនឹងចំណង់នៃការសិក្សាវិញ និស្សិតបានយល់ឃើញថា ការសិក្សាពីរជំនាញធ្វើឲ្យពួកគេខិតខំរៀនជាងមុន (៥១.៧០%) ប៉ុន្តែក៏មាននិស្សិតប្រមាណជាង២៣%ចង់បោះបង់មួយជំនាញផងដែរ។

**ក្រាហ្វិក ៣.៩៖ បង្ហាញពីឥទ្ធិពលនៃការសិក្សាពីរជំនាញលើការគ្រប់គ្រងពេលវេលារបស់និស្សិត**




- ទិន្នន័យក្នុងក្រាហ្វិក ៣.៩. បានបង្ហាញថា ជាងពាក់កណ្តាលនៃនិស្សិតសិក្សាពីរជំនាញ (៥១.៧០%) មានបញ្ហាការគ្រប់គ្រងពេលវេលាដោយពួកគេមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀននិងសម្រាក។ បន្ថែមពីលើនេះ ក៏មាននិស្សិតច្រើននាក់ដែរ (៤០%) មានពេលវេលាគ្រប់គ្រាន់សម្រាប់រៀន តែខ្វះពេលសម្រាក។ បញ្ហាទាំងពីរនេះ បានបង្កផលប៉ះពាល់ដល់លទ្ធផលសិក្សានិងសុខភាពរបស់និស្សិត។

ក្រាហ្វិក ៣.៥៖ បង្ហាញពីឥទ្ធិពលនៃការសិក្សាពីរជំនាញលើស្ថានភាពសុខភាពរបស់និស្សិត




- ដោយការគ្រប់គ្រងពេលវេលាមានទំនាក់ទំនងវិជ្ជមាន ជាមួយនឹងសុខភាពរបស់និស្សិត ទិន្នន័យខាងលើបានបង្ហាញអត្ថន័យស្របគ្នាថា និស្សិតសិក្សាពីរជំនាញដែលមានបញ្ហាការគ្រប់គ្រងពេលវេលាខាងលើ បានជួបប្រទះបញ្ហាសុខភាពចម្បងៗចំនួនពីរគឺ ការកើតមានអារម្មណ៍Stress ពិបាកចិត្ត វិលមុខ អស់កម្លាំង និងការគេងមិនគ្រប់គ្រាន់។

### ក្រាហ្វិក ៣.៦៖ បង្ហាញពីមធ្យមភាគសិក្សា (GPA)របស់និស្សិតសិក្សាពីរជំនាញ




សរុបជារួមមក គេសង្កេតឃើញនិស្សិតសិក្សាពីរជំនាញភាគច្រើនទទួលបាននិទ្ទេសល្អគឺនិទ្ទេសB (GPA=3.5) ដែលមានចំនួនជាង៦៧% និងនិទ្ទេសល្អបង្គួរគឺនិទ្ទេសC (GPA=2.5) ដែលមានចំនួន២៥%។

## ៣.២. ការវិភាគ និងបកស្រាយទំនាក់ទំនងរវាងអថេរឯករាជ្យនិងមធ្យមភាគសិក្សា (GPA)

ក្រាហ្វិក ៣.៧៖ បង្ហាញពីឥទ្ធិពលនៃកត្តាជំរុញលើមធ្យមភាគសិក្សា (GPA) របស់និស្សិត




យោងតាមក្រាហ្វិក ៣.៧. និទ្ទេសB ជានិទ្ទេសដែលនិស្សិតសិក្សាពីរជំនាញភាគច្រើនទទួលបាន ដែលក្នុងចំណោមនិស្សិត៦០នាក់ដែលជាគំរូសិក្សារបស់យើង មាននិស្សិតចំនួន៤០នាក់ទទួលបាននិទ្ទេសនេះ។ លើសពីនេះ យើងសង្កេតឃើញថា ចំពោះពួកគេ កត្តាដែលមានឥទ្ធិពលខ្លាំងជាងគេជំរុញឲ្យគេសិក្សាពីរជំនាញគឺ កត្តាឱកាសការងារ (២០នាក់) និងកត្តាខ្លួនឯង (១១នាក់)។

**ក្រាហ្វិក ៣.៨៖ បង្ហាញពីឥទ្ធិពលនៃការចូលរួមក្នុងថ្នាក់លើមធ្យមភាគសិក្សា (GPA) របស់និស្សិត**




ក្រាហ្វិក ៣.៨. បានបង្ហាញលទ្ធផលស្របគ្នានឹងក្រាហ្វិក ៣.២. ដែលបានបង្ហាញថា កិច្ចការស្រាវជ្រាវគឺជាបញ្ហាចម្បងដែលនិស្សិតសិក្សាពីរជំនាញបានជួបប្រទះ។ ជាក់ស្តែង ក្នុងក្រាហ្វិក ៣.៨. ក្នុងចំណោមនិស្សិតនិទ្ទេសB ទាំង៤០នាក់ មាននិស្សិតដល់ទៅ២៩នាក់ជួបប្រទះបញ្ហាការធ្វើកិច្ចការស្រាវជ្រាវ។ គួរកត់សម្គាល់ផងដែរថា បើទោះបីជាជួបប្រទះបញ្ហានេះក៏ដោយ ក៏និស្សិតនៅតែអាចរក្សាលទ្ធផលសិក្សារបស់ខ្លួនបានល្អដោយសារ ពួកគេបានខិតខំប្រឹងប្រែងនិងចំណាយពេលវេលាច្រើនក្នុងការរៀនសូត្រ។

**ក្រាហ្វិក ៣.៩៖ បង្ហាញពីឥទ្ធិពលនៃចំណង់នៃការសិក្សាលើមធ្យមភាគសិក្សា (GPA) របស់និស្សិត**




យោងតាមក្រាហ្វិក ៣.៩. យើងសង្កេតថា មូលហេតុមួយដ៏សំខាន់ដែលធ្វើឲ្យនិស្សិតសិក្សាពីរជំនាញភាគច្រើនទទួលបានលទ្ធផលសិក្សាល្អ (និទ្ទេសB) គឺ ដោយសារការសិក្សាពីរជំនាញធ្វើឲ្យនិស្សិតខិតខំសិក្សាជាងមុន។ ជាក់ស្តែង ក្នុងចំណោមនិស្សិតនិទ្ទេសB ទាំង៤០នាក់ មាននិស្សិតចំនួនរហូតដល់២១នាក់បានបញ្ជាក់ថា ពួកគេបានខិតខំប្រឹងប្រែងរៀនសូត្រជាងមុន។

**ក្រាហ្វិក ៣.១០៖ បង្ហាញពីឥទ្ធិពលនៃការគ្រប់គ្រងពេលវេលាលើមធ្យមភាគសិក្សា (GPA) របស់និស្សិត**




ក្រាហ្វិក ៣.១០. បានបង្ហាញលទ្ធផលស្របគ្នានឹងការបកស្រាយរបស់ក្រាហ្វិក ៣.៤. ដែលថា និស្សិតសិក្សាពីរជំនាញភាគច្រើនមានបញ្ហាការគ្រប់គ្រងពេលវេលាដោយមានពេលវេលាមិនគ្រប់គ្រាន់សម្រាប់រៀន និងសម្រាក។ យោងតាមក្រាហ្វិកខាងលើនេះ យើងអាចពន្យល់បានថា ក្រៅពីចំណង់នៃការសិក្សា ការគ្រប់គ្រងពេលវេលាក៏ចូលរួមចំណែកសំខាន់ក្នុងការធ្វើឲ្យនិស្សិតសិក្សាពីរជំនាញទទួលបាននិទ្ទេសដ៏ល្អដែរ។ ជាក់ស្តែង ក្នុងចំណោមនិស្សិតនិទ្ទេស B ទាំង៤០នាក់ មាននិស្សិត២០នាក់ បានចំណាយពេលវេលាយ៉ាងច្រើនរៀននៅសាលារហូតធ្វើឲ្យមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀនបន្ថែមខ្លួនឯង ហើយមាននិស្សិត១៦នាក់ទៀតបានចំណាយពេលច្រើនសម្រាប់រៀនរហូតគ្មានពេលសម្រាកគ្រប់គ្រាន់។ ដោយសារតែមិនមានពេលសម្រាកគ្រប់គ្រាន់នេះហើយ ទើបធ្វើឲ្យនិស្សិតជួបប្រទះបញ្ហាសុខភាព។

## ក្រាហ្វិក ៣.១១.៖ បង្ហាញពីឥទ្ធិពលនៃសុខភាពរបស់និស្សិតលើមធ្យមភាគសិក្សា (GPA)




ដោយផ្សារភ្ជាប់អត្ថន័យនឹងក្រាហ្វិក ៣.១០. ខាងលើ ក្រាហ្វិក ៣.១១. បានបង្ហាញពីបញ្ហាសុខភាពដែលនិស្សិតសិក្សាពីរជំនាញបានជួបប្រទះ ដែលធ្វើឲ្យប៉ះពាល់ដល់លទ្ធផលសិក្សារបស់ពួកគេ។ គេសង្កេតឃើញថា ក្នុងចំណោមនិស្សិតនិទ្ទេស B ទាំង៤០នាក់ មាននិស្សិត ១៨ នាក់បានជួបប្រទះបញ្ហាអារម្មណ៍ Stress និងមាននិស្សិត ១៤នាក់ទៀត បានជួបបញ្ហាការគេងមិនបានគ្រប់គ្រាន់ ដែលដូចគ្នានឹងការបកស្រាយនៅក្រាហ្វិក ៣.១០. ដែរ។ ការកើតមានបញ្ហាអារម្មណ៍ Stress នេះបណ្ដាលមកពីបន្ទុកការងារសាលាច្រើន ហើយនិស្សិតគ្រប់គ្រងពេលវេលារបស់ខ្លួនមិនបានល្អ។

## ក្រាហ្វិក ៣.១២.៖ បង្ហាញពីចំណាប់អារម្មណ៍របស់និស្សិតទៅលើការសិក្សាពីរជំនាញ




នៅក្នុងក្រាហ្វិក ៣.១២. នេះ និស្សិត៦០នាក់ដែលជាគំរូសិក្សារបស់យើង បានបង្ហាញថាពីចំណាប់អារម្មណ៍ជារួមរបស់ពួកគេទៅលើការសិក្សាពីរជំនាញក្នុងពេលតែមួយ ដែលក្នុងនោះមាននិស្សិតភាគច្រើន (៦៦.៧០%) ពេញចិត្តនឹងការសិក្សាពីរជំនាញរបស់ពួកគេ ខណៈពេលដែលនិស្សិត ៣៣.៣០% ទៀតមិនពេញចិត្តនឹងការសិក្សាពីរជំនាញរបស់ពួកគេទេ។

## ៣.៣. លទ្ធផលនៃការស្រាវជ្រាវ

ដោយប្រើអថេរឯករាជ្យទាំងបួនដូចជា ការចូលរួមក្នុងថ្នាក់ ចំណង់នៃការសិក្សា ការគ្រប់គ្រងពេលវេលា និងសុខភាពរបស់និស្សិត ជាមួយនឹងអថេរមិនឯករាជ្យគឺ មធ្យមភាគសិក្សារបស់និស្សិត (GPA) យើងទាញបាន Regression Model សង្ខេប (តារាង ៣.១.) ដើម្បីបកស្រាយពីឥទ្ធិពលនៃការសិក្សាពីរជំនាញលើលទ្ធផលសិក្សារបស់និស្សិត។

**តារាង ៣.១៖ បង្ហាញពី Regression Model សង្ខេប**

**Coefficients[a]**

| Model | | Unstandardized Coefficients | | Standardized Coefficients | | |
|---|---|---|---|---|---|---|
| | | B | Std. Error | Beta | T | Sig. |
| 1 | (Constant) | 2.213 | .188 | | 11.769 | .000 |
| | Assignment | .076 | .172 | .058 | .443 | .660 |
| | Study harder | -.226 | .157 | -.187 | -1.435 | .157 |
| | Less study time & sleep | .286* | .169 | .237 | 1.693 | .096 |
| | Stress | -.072 | .169 | -.059 | -.426 | .672 |

a. Dependent Variable: Grade/GPA

*** Significant at risk 1% = P.value: 0.01

** Significant at risk 5% = P.value: 0.05

* Significant at risk 10% = P. value: 0.10

ផ្អែកតាមតារាងវិភាគលទ្ធផលខាងលើ អថេរ Assignment, Study harder និងStress មិនមានឥទ្ធិពលដល់លទ្ធផលសិក្សារបស់និស្សិតទេ។ កត្តាដែលប៉ះពាល់ធំបំផុតដល់លទ្ធផលសិក្សាគឺ Less study time and sleep ដែលមានកម្រិតហានិភ័យ ១០%។ នេះមានន័យថា កាលណានិស្សិតគ្រប់គ្រងពេលវេលាមិនបានល្អ លទ្ធផលសិក្សាពីរជំនាញអាចមានបញ្ហាប្រឈមនឹងការធ្លាក់ ឬលទ្ធផលសិក្សាមិនសូវល្អ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ការសិក្សាមួយនេះធ្វើឲ្យយើងទទួលបាននូវព័តមានជាច្រើន ដែលទាក់ទងនឹងឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយទៅលើលទ្ធផលសិក្សារបស់និស្សិត ដែលមានទំនាក់ទំនងជាមួយនឹងការចូលរួមក្នុងថ្នាក់ (ដែលរួមមានវត្តមាន ការឆ្លើយសំនួរនៅក្នុងថ្នាក់ ការពិភាក្សាក្រុម កិច្ចការស្រាវជ្រាវ...) ចំណង់ចំណូលចិត្តសិក្សា ការគ្រប់គ្រងពេលវេលា សុខភាពរបស់និស្សិត និងមធ្យមភាគនៃការសិក្សា។ ក្នុងចំណោមនិស្សិតដែលបានចូលរួមឆ្លើយសំណួរចំនួន ៦០នាក់ មាននិស្សិតប្រមាណ ៩០% បានឆ្លើយថា ការសិក្សាពីរជំនាញក្នុងពេលតែមួយមានឥទ្ធិពលអវិជ្ជមានទៅលើការចូលរួមនៅក្នុងថ្នាក់ (សំណួរទី២) ដែលក្នុងនោះ មាននិស្សិត ៦៨% បានជួបប្រទះបញ្ហាដូចជាអវត្តមានច្រើន អសកម្មក្នុងការឆ្លើយសំណួរនៅក្នុងថ្នាក់ ការធ្វើកិច្ចការស្រាវជ្រាវមិនបានគ្រប់គ្រាន់ និងការធ្វើបទបង្ហាញមិនបានល្អ ដោយសារតែពួកគេមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀនសូត្រ ដែលនាំឲ្យការយល់ដឹងអំពីមុខជំនាញរបស់ខ្លួនមិនសូវស៊ីជម្រៅ។ ចំណែកឯ ២២% ផ្សេងទៀត បានជួបប្រទះបញ្ហាការពិបាកយល់មេរៀនច្រើនក្នុងពេលតែមួយ អស់កម្លាំង ហេវហត់ អារម្មណ៍មិនល្អ និងសុខភាពចុះខ្សោយជាដើម។ ផ្ទុយទៅវិញ មាននិស្សិតតែ ៦នាក់ (១០%) បានឆ្លើយថា ការសិក្សាពីរជំនាញនៅក្នុងពេលតែមួយគឺល្អ ដោយសារពួកគេទួលបានចំណេះដឹងច្រើន កាត់បន្ថយពេលវេលាដើរលេង និងខិតខំរៀនជាងមុនរហូតទទួលបានលទ្ធផលល្អ។

សរុបជារួម ទោះបីជាការសិក្សាពីរជំនាញក្នុងពេលតែមួយមានឥទ្ធិពលអវិជ្ជមានច្រើនទៅលើការសិក្សារបស់និស្សិត ដូចជាអវត្តមានច្រើន មិនមានពេលវេលាគ្រប់គ្រាន់សម្រាប់អានសៀវភៅបន្ថែម និងធ្វើកិច្ចការស្រាវជ្រាវ និងប៉ះពាល់ដល់សុខភាព ដូចជាហេវហត់ អស់កម្លាំង អារម្មណ៍មិនល្អក៏និស្សិតភាគច្រើនរហូតប្រមាណ ៦០% មានការពេញចិត្តជាមួយការសិក្សាពីរជំនាញក្នុងពេលតែមួយ ដោយហេតុផលថា ពួកគេទទួលបានចំណេះដឹងច្រើនពីការរៀនច្រើនមុខវិជ្ជា ចំណេញពេលវេលា ដោយសារពួកគេនឹងទទួលបានសញ្ញាបត្រពីរក្នុងពេលតែមួយ ជួបគ្រូល្អៗច្រើន មានមិត្តភក្តិច្រើន ដែលជាបណ្តាញយ៉ាងសំខាន់នៅក្នុងសង្គម ចេះប្រឹងប្រែង និងហាត់ពត់លត់ដំខ្លួន និងមានឱកាសការងារច្រើននៅពេលរៀនចប់។ លើសពីនេះទៀត ពួកគេបានបន្តថា ការរៀនពីរជំនាញធ្វើឲ្យពួកគេអាចរៀនបានពីរដងចំពោះមុខវិជ្ជាខ្លះ ចេះបែងចែកពេលវេលា

សម្រាប់ការសម្រាកនិងការរៀន និងចេះរៀបចំផែនការ។ មួយវិញទៀត និស្សិតបានបន្តថា ការសិក្សាពីរជំនាញក្នុងពេលតែមួយគឺពិតជាល្អ ប្រសិនបើការសិក្សានោះត្រូវបានជ្រើសរើសដោយការស្រលាញ់ពេញចិត្តរបស់ខ្លួន។ ទន្ទឹមគ្នានេះដែរ ក៏មាននិស្សិតប្រមាណ ៩០% មិនសូវពេញចិត្តនឹងការសិក្សាពីរជំនាញក្នុងពេលតែមួយ ដោយសារពួកគេមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់សម្រាក សម្រាប់ស្រាវជ្រាវ សម្រាប់ការជួបជុំគ្រួសារ និងការចូលរួមនៅក្នុងសង្គម។

## ២. អនុសាសន៍

ការសិក្សាពីរជំនាញក្នុងពេលតែមួយគឺជាកិច្ចការមួយដ៏លំបាក ពីព្រោះវាទាមទារឲ្យនិស្សិតខិតខំប្រឹងប្រែងរៀនសូត្រអស់ពីកម្លាំងកាយចិត្ត។ អាស្រ័យហេតុនេះហើយ ទើបបានជាការសិក្សាពីរជំនាញបានជះឥទ្ធិពលអវិជ្ជមានលើលទ្ធផលសិក្សារបស់និស្សិត ប្រសិនបើពួកគេគ្រប់គ្រងពេលវេលាមិនបានល្អ។ ដូច្នេះ មុនពេលសម្រេចចិត្តសិក្សាពីរជំនាញ និស្សិតគួរស្វែងយល់ឲ្យច្បាស់ពីបញ្ហាដែលអាចកើតមាន ពិសេសគឺសមត្ថភាពខ្លួនឯងផ្ទាល់ថា តើខ្លួនមានសមត្ថភាពរ៉ាប់រងការងារសាលា និងកិច្ចការស្រាវជ្រាវដ៏ច្រើនទាំងនោះបានដែរឬទេ។ លើសពីនេះ ប្រសិនបើនិស្សិតបានសម្រេចចិត្តសិក្សាពីរជំនាញហើយ ពួកគេគួរតែរៀនគ្រប់គ្រងពេលវេលាឲ្យបានល្អ ដោយត្រូវរៀនរៀបចំកាលវិភាគរៀនសម្រាប់ខ្លួនឯង យកចិត្តទុកដាក់មើលថែសុខភាពឲ្យបានល្អ ដោយសម្រាកនិងញ៉ាំឲ្យបានគ្រប់គ្រាន់ និងស្វែងរកជំនួយពីលោកគ្រូ អ្នកគ្រូករណីជួបប្រទះបញ្ហាក្នុងការសិក្សា។ បន្ថែមពីលើនេះ និស្សិតគួរជ្រើសរើសមុខជំនាញដែលខ្លួនពេញចិត្តបំផុត ទើបអាចផ្តល់កម្លាំងចិត្តមោះមុតក្នុងការខិតខំរៀន ដើម្បីបញ្ចប់ការសិក្សាទាំងពីរដោយជោគជ័យ។ ជាចុងបញ្ចប់ និស្សិតគួរជ្រើសរើសមុខវិជ្ជាណាដែលអាចបំពេញគ្នាបាន ដើម្បីងាយស្រួលក្នុងការស្វែងយល់ អត្ថន័យមេរៀន និងពង្រឹងចំណេះដឹងរបស់ខ្លួន។

# ឯកសារយោង

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (២០១៤-២០១៨), រាជរដ្ឋាភិបាលកម្ពុជា

Alison F. Del Rossi and Joni Hersch. (2007, March 16). Double your major, double your return? *Economics of Education Review, 27*(2008). doi:doi:10.1016/j.econedurev.2007.03.001

Anonymous. (2015, April 28). Kids City′s STEM competition to spark passion for science in Cambodian youth. Retrieved May 25,2017, from The Phnom Penh Post: http://www.phnompenhpost.com.

Armbrecht, A. (2016, February). Which degree will get you hired? Retrived May 25, 2017, from World Economic Forum: https://www.weforum.org/agenda/2016/02/which-degree-will-get-you-hired/.

Ayres, D. (2000). Tradition, Modernity, and the Development of Education in Cambodia. Comparative Education Review, 4(4).

Ayres, D. (1999). The Khmer Rouge and education: beyond the discourse of destruction. History of Education. History of Education. Retrieved from http://dx.doi.org/10.1080/004676099284744.

Blanquat, S., & Associates . (2016). STEM Careers of the Future. Phnom Penh: British Embassy Phnom Penh.

Chendler, D. (2008). A history of Cambodia (4 thEdit). Boulder, Colo: Westview Press.

Ciniro, E. (2014, November 27). *5 sings double majoring may be right for you*. (Vasity Tutors) Retrieved from USA Today College: http://college.usatoday.com/2014/11/27/5-signs-double-majoring-may-be-right-for-you/

Dy, S. (2004). Strategies and Policies for Basic Education in Cambodia: Historycal Perspective . International Education Journal,, 90-97.

*Double Majors in the United States*. (2016, November 16). Retrieved from Wikipedia: https://en.wikipedia.org/wiki/Double_majors_in_the_United_States

Ford, D. (2006). Cambodia-Growing and Pains. International Higher Education (44), 2.

*Higher Education*. (n.d.). Retrieved January 7, 2017, from Minstry of Education, Youth and Sport: http://www.moeys.gov.kh/en/education/higher-education.html#.WRJiSM5OLIV

Holman, Z. (2015). UK backs STEM push. Retrived May 26, 2017, from The Phnom Penh Post: http://www.phnompenhpost.com/national/uk-backs-stem-push

James H. Williams, Yuto Kitamura, C. Sopcheak Keng. (2014, March). Higher Education in Cambodia: Expansion and quality improvement. *Higher Education Forum, Vol11*. Retrieved from https://ir.lib.hiroshima-u.ac.jp/files/public/3/37025/20150423092237305377/HigherEducationForum_11_67.pdf

Kaing, S. (2016). STEM Education in Cambodia. Retrived May 26, 2017, from ResearchGate: https://www.researchgate.net/publication/308725757_STEM_Education_in_Cambodia

Kung, (2014, June 4). How Universities Can Help Improve the Quality of Education. Retrived May 27, 2017, from The Cambodia Daily: https://www.cambodiadaily.com/opinion/how-universities-can-help-improve-the-quality-of-education-60461/

Mark. (2016, Febraury 17). Cambodia׳s Skills Challenge; Bridging the Gap. Retrived May 27, 2017, from ASEANForum : http://aseanforum.asia.

Masson, G., & Fergusso, L. (1997). A culture under siege: post-colonial higher education and teacher education in Cambodia from 1953 to 1979. History of Education.

MoEYS. (2011). Summary Report on the Education, Youth and Sport Performance in the Academic Year 2009-2010 and the Academic Year 2010-2011 Goals. Phnom Penh, Cambodia.: MoEYS.

Parikh, T. (2016, Jaunury 18). Dearth of Science, Tech Skills Threatens Growth. Retrieved May 28, 2017, from The Cambodia Daily: https://www.cambodiadaily.com/news/dearth-of-science-tech-skills-threatens-growth-106645/

Potter, K. (2016, September 15). *How to double major and double your knowledge at a U.S. university?* Retrieved from Bachelorsportal: http://www.bachelorsportal.eu/articles/2007/how-to-double-major-and-double-your-knowledge-at-a-us-university.html

Pit, C.,& Ford, D. (2004). Cambodian Higher Education: Mixed Visions In P. G. A. & T. Umakoshi (Ed.), Asian Universities: Historical Perspectives and Contemporary Challenges. Baltimore and London: The Johns Hopkins University Press.

Richard N. Pitt and Steven A. Tepper. (2012). *Double Majors: Influences, Identities & Impacts.* The Curb Center for Art, Enterprise and Public Policy, Vanderbilt. Retrieved from http://stevenjtepper.com/wp-content/uploads/2013/12/Teagle-Report-Final-3-11-13.pdf

Roath, S. (2015, September 30). *One major or two?* Retrieved from Khmer Times: http://www.khmertimeskh.com/news/16370/one-major-or-two-/

Sam, R. (2012). Cambodia´s Higher Education Development in Historical Perspectives (1863-2012). International Journal of Learning & Development, 225.

Schachner, A. (2015, November 20). *My secret life attending two university at the same time*. Retrieved from Macleans: http://www.macleans.ca/education/my-secret-life-attending-two-universities-at-the-same-time/

Sen, H. (2011). Keynote Address at the Conferment of Certificate and Degree to Graduates of the University of Human Resources. Phnom Penh, Cambodia.

Tepper, R. N. (2012). Double Majors Influences, Identities, and Impacts. *A Cerb Center*, 33 to 37.

UNESCO. (2011). Higher Education in South-East Asia. Bangkok, Thailand: UNESCO Asia and Pacific Regional Bureau for Education.

Virak, Y. (2009). Student Mobility in Southeast Asia: the Case of Cambodia . Kuala Lumpur, Malaysia : The paper presented at the regional seminar on student mobility in southeast Asia.

Walter, J. (2013, November 13). Cambodian education lags behind. Retrived May 29, 2017, from The Phnom Penh Post: http://www.phnompenhpost.com/analysis-and-op-ed/cambodian-education-lags-behind

Zafar, B. (2010). *Double majors: One for me, one for my parents?* Staff Report, Federal Reserve Bank of New York. Retrieved from http://files.eric.ed.gov/fulltext/ED517638.pdf

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ ថ្ងៃសម្ភាសន៍៖ ………………………..
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អ្នកសម្ភាសន៍៖………………………….

# កម្រងសំណួរ

កម្រងសំណួរនេះ មានគោលបំណងស្វែងរកពត៌មាននិស្សិតដែលសិក្សាពីរជំនាញក្នុងពេលតែមួយនៅកម្រិតថ្នាក់បរិញ្ញាបត្រ។ លទ្ធផលនៃកម្រងសំណួរនេះ ត្រូវបានប្រើប្រាស់សម្រាប់វិភាគពីឥទ្ធិពលនៃការសិក្សាពីរជំនាញក្នុងពេលតែមួយទៅលើលទ្ធផលនៃការសិក្សារបស់និស្សិត។ សូមនិស្សិតម្នាក់ៗមេត្តាជួយឆ្លើយដោយស្មោះត្រង់ទៅតាមការពិតជាក់ស្តែងដែលខ្លួនបានជួបប្រទះ។

យើងខ្ញុំសូមធានាថា ពត៌មានរបស់និស្សិតម្នាក់ៗនឹងត្រូវបានរក្សាជាការសំងាត់។ សូមអរគុណចំពោះការចំណាយពេលវេលាដ៏មានតម្លៃ និងការចូលរួមសហការណ៍របស់និស្សិតទាំងអស់គ្នា។ ចំពោះកម្រងសំណួរខាងក្រោម សូមគូស(✓)ត្រង់ចម្លើយរបស់និស្សិត។

បច្ចុប្បន្នជានិស្សិតរៀននៅសាកលវិទ្យាល័យ…………………………………ជំនាញ……………………………….
និងសាកលវិទ្យាល័យ……………………………………………ជំនាញ…………………………………។

១.តើកត្តាអ្វីខ្លះដែលជំរុញឲ្យអ្នកសំរេចចិត្តរៀនពីរជំនាញក្នុងពេលតែមួយ? **(រើសយកតែមួយគត់)**

1☐ គ្រួសារបង្ខំ
2☐ មិត្តភក្តិអូសទាញ
3☐ សំរេចចិត្តរៀនខ្លួនឯង
4☐ រំពឹងថាទទួលបានឱកាសការងារធ្វើល្អៗនិងច្រើនជាងគេ
5☐ ដោយសារទទួលបានអាហារូបករណ៍ពីសាលា
6☐ ផ្សេងពីនេះ ……………………

២.តើការសិក្សាពីរជំនាញមានផលប៉ះពាល់ដូចម្តេចដល់ការចូលរួមរបស់អ្នកនៅក្នុងថ្នាក់? **(រើសយកតែមួយគត់ដែលប៉ះពាល់ខ្លាំងជាងគេ)**

1☐ វត្តមាន
2☐ ការចូលរួមឆ្លើយសំណួរក្នុងថ្នាក់
3☐ ការពិភាក្សាក្រុម
4☐ កិច្ចការស្រាវជ្រាវមេរៀននិងការធ្វើបទបង្ហាញ
5☐ ផ្សេងពីនេះ ……………………

៣.ចំពោះចម្លើយដែលអ្នកបានជ្រើសយកនៅសំណួរទី២ តើវាទទួលរងផលប៉ះពាល់ដូចម្តេច? **(រើសយកតែមួយគត់)**

1☐ វិជ្ជមាន
2☐ អវិជ្ជមាន
3☐ មិនដឹង

៤.ប្រសិនបើជ្រើសយកចម្លើយ "វិជ្ជមាន" តើវាមានលក្ខណៈបែបណា?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………។

៥.ប្រសិនបើជ្រើសយកចម្លើយ "អវិជ្ជមាន" តើវាមានលក្ខណៈបែបណា?

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………។

៦.តើអ្នកគិតថា ការរៀនពីរជំនាញក្នុងពេលតែមួយទទួលបានលទ្ធផលសិក្សា ឬមធ្យមភាគនៃការសិក្សា (GPA) របស់អ្នកយ៉ាងដូចម្តេច? **(រើសយកតែមួយគត់)**

1☐ ទទួលបានពិន្ទុល្អប្រសើរ A= 4.0 (score: 85% – 100%)

2☐ ទទួលបានពិន្ទុល្អ B= 3.0 – 3.99 (score: 70% – 84%)

3☐ ទទួលបានពិន្ទុល្អបង្គួរ C= 2.0 – 2.99 (score: 50% – 69%)

4☐ ទទួលបានពិន្ទុមធ្យម D= 1.5 (score: 45% – 49%)

5☐ ទទួលបានពិន្ទុមិនល្អ E=1.0 (score: <44%)

៧.តើការរៀនពីរជំនាញក្នុងពេលតែមួយមានផលប៉ះពាល់លើចំណង់នៃការសិក្សា (ការរំលឹកមេរៀន ការអាន និងការស្រាវជ្រាវមេរៀនបន្ថែម) របស់អ្នកយ៉ាងដូចម្តេច? **(រើសយកតែមួយគត់ដែលប៉ះពាល់ខ្លាំងជាងគេ)**

1☐ ខិតខំប្រឹងប្រែងរៀនជាងមុន

2☐ មិនសូវខិតខំប្រឹងប្រែងរៀន

3☐ ចង់បោះបង់ចោលមួយមុខជំនាញ

4☐ ចង់ឈប់រៀនទាំងពីរជំនាញ

5☐ ផ្សេងពីនេះ ………………

៨.តើការរៀនពីរជំនាញក្នុងពេលតែមួយមានផលប៉ះពាល់លើការគ្រប់គ្រងពេលវេលារបស់អ្នកយ៉ាងដូចម្តេច?

**(រើសយកតែមួយគត់)**

1☐ មានពេលវេលាគ្រប់គ្រាន់សម្រាប់រៀននិងសម្រាក

2☐ មានពេលវេលាមិនគ្រប់គ្រាន់សម្រាប់រៀននិងសម្រាក

3☐ មានពេលវេលាគ្រប់គ្រាន់សម្រាប់រៀន តែខ្វះពេលសម្រាក

៩.តើការរៀនពីរជំនាញក្នុងពេលតែមួយមានផលប៉ះពាល់លើសុខភាពរបស់អ្នកយ៉ាងដូចម្ដេច? **(រើសយកតែមួយគត់ដែលជួបប្រទះញឹកញាប់ជាងគេ)**

1☐ ការបរិភោគបានគ្រប់គ្រាន់ និងទៀងទាត់

2☐ ការបរិភោគមិនបានគ្រប់គ្រាន់ និងមិនទៀងទាត់

3☐ ការគេងបានគ្រប់គ្រាន់

4☐ ការគេងមិនបានគ្រប់គ្រាន់

5☐ មានបញ្ហាអារម្មណ៍Stress ពិបាកចិត្ត វិលមុខ អស់កម្លាំង

6☐ ឧស្សាហ៍ឈឺ (ផ្ដាសាយ៍ គ្រុនក្ដៅ ឈឺភ្នែក ។ល។)

១០. ជារួម តើអ្នកគិតដូចម្ដេចចំពោះការរៀនពីរជំនាញក្នុងពេលតែមួយ? **(រើសយកតែមួយគត់)**

1☐ ពេញចិត្ត

2☐ មិនសូវពេញចិត្ត

១១.ករណីពេញចិត្តរៀនពីរជំនាញក្នុងពេលតែមួយ សូមចែករំលែកបទពិសោធន៍ល្អៗ។

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………………។

១២.ករណីមិនពេញចិត្ត សូមផ្ដល់ជាមតិយោបល់សម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយ។

……………………………………………………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………………។

*សូមអរគុណ!*

# SPSS Data Analysis
## Frequencies

**Statistics**

push factor

| | | |
|---|---|---|
| N | Valid | 60 |
| | Missing | 0 |

**Push Factor**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Family | 1 | 1.7 | 1.7 | 1.7 |
| | Friend | 1 | 1.7 | 1.7 | 3.3 |
| | Itself | 16 | 26.7 | 26.7 | 30.0 |
| | Job opportunity and expected earning | 30 | 50.0 | 50.0 | 80.0 |
| | Scholarship | 12 | 20.0 | 20.0 | 100.0 |
| | Total | 60 | 100.0 | 100.0 | |

**Grade/GPA**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | A | 3 | 5.0 | 5.0 | 5.0 |
| | B | 40 | 66.7 | 66.7 | 71.7 |
| | C | 15 | 25.0 | 25.0 | 96.7 |
| | D | 2 | 3.3 | 3.3 | 100.0 |
| | Total | 60 | 100.0 | 100.0 | |

**Study Habit**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Study harder | 31 | 51.7 | 51.7 | 51.7 |
| | Become lazier and have less feeling to study | 11 | 18.3 | 18.3 | 70.0 |
| | Want to drop one major | 14 | 23.3 | 23.3 | 93.3 |
| | Want to quit both majors | 1 | 1.7 | 1.7 | 95.0 |
| | Other | 3 | 5.0 | 5.0 | 100.0 |
| | Total | 60 | 100.0 | 100.0 | |

**Time Management**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Have enough time to study and rest | 5 | 8.3 | 8.3 | 8.3 |
| | Do not have enough time to study and rest | 31 | 51.7 | 51.7 | 60.0 |
| | Have enough time to study but do not have time to rest | 24 | 40.0 | 40.0 | 100.0 |
| | Total | 60 | 100.0 | 100.0 | |

**Health Condition**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Have a regular eating with enough nutrition | 3 | 5.0 | 5.0 | 5.0 |
| | Do not have a regular eating and do not have enough nutrition | 7 | 11.7 | 11.7 | 16.7 |
| | Have enough sleep | 1 | 1.7 | 1.7 | 18.3 |
| | Do not have enough sleep | 22 | 36.7 | 36.7 | 55.0 |
| | Feel stressful, sad, dizzy and tired | 26 | 43.3 | 43.3 | 98.3 |
| | Easily get sick (cold, fever, eyesight problem, etc.) | 1 | 1.7 | 1.7 | 100.0 |
| | Total | 60 | 100.0 | 100.0 | |

**Feeling towards DMS**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Appreciate | 40 | 66.7 | 66.7 | 66.7 |
| | Not appreciate | 20 | 33.3 | 33.3 | 100.0 |
| | Total | 60 | 100.0 | 100.0 | |

# Regression

**Variables Entered/Removed[a]**

| Model | Variables Entered | Variables Removed | Method |
|---|---|---|---|
| 1 | stress, sharder, Assig, lesst[b] | . | Enter |

a. Dependent Variable: Grade/GPA

b. All requested variables entered.

**Model Summary**

| Model | R | R Square | Adjusted R Square | Std. Error of the Estimate |
|---|---|---|---|---|
| 1 | .331[a] | .109 | .044 | .593 |

a. Predictors: (Constant), stress, sharder, Assig, lesst

**ANOVA[a]**

| Model | | Sum of Squares | df | Mean Square | F | Sig. |
|---|---|---|---|---|---|---|
| 1 | Regression | 2.374 | 4 | .594 | 1.686 | .166[b] |
| | Residual | 19.359 | 55 | .352 | | |
| | Total | 21.733 | 59 | | | |

a. Dependent Variable: Grade/GPA

b. Predictors: (Constant), stress, sharder, Assig, lesst

**Coefficients[a]**

| Model | | Unstandardized Coefficients | | Standardized Coefficients | t | Sig. |
|---|---|---|---|---|---|---|
| | | B | Std. Error | Beta | | |
| 1 | (Constant) | 2.213 | .188 | | 11.769 | .000 |
| | Assig | .076 | .172 | .058 | .443 | .660 |
| | sharder | -.226 | .157 | -.187 | -1.435 | .157 |
| | lesst | .286 | .169 | .237 | 1.693 | .096 |
| | stress | -.072 | .169 | -.059 | -.426 | .672 |

a. Dependent Variable: Grade/GPA

**Case Processing Summary**

| | Cases | | | | | |
|---|---|---|---|---|---|---|
| | Valid | | Missing | | Total | |
| | N | Percent | N | Percent | N | Percent |
| Grade/GPA * Class participation | 60 | 100.0% | 0 | 0.0% | 60 | 100.0% |

**Study Habit * Grade/GPA Crosstabulation**

Count

| | | Grade/GPA | | | | Total |
|---|---|---|---|---|---|---|
| | | A | B | C | D | |
| Study habit | Study harder | 3 | 21 | 7 | 0 | 31 |
| | Become lazier and have less feeling to study | 0 | 7 | 4 | 0 | 11 |
| | Want to drop one major | 0 | 9 | 3 | 2 | 14 |
| | Want to quit both majors | 0 | 0 | 1 | 0 | 1 |
| | Other | 0 | 3 | 0 | 0 | 3 |
| Total | | 3 | 40 | 15 | 2 | 60 |

**Class participation * Grade/GPA Crosstabulation**

Count

| | | Grade/GPA | | | | Total |
|---|---|---|---|---|---|---|
| | | A | B | C | D | |
| Class participation | Attendance | 2 | 3 | 1 | 0 | 6 |
| | Answering in the class | 0 | 2 | 1 | 0 | 3 |
| | Group discussion | 0 | 2 | 1 | 0 | 3 |
| | Assignment and presentation | 1 | 29 | 10 | 2 | 42 |
| | Other | 0 | 4 | 2 | 0 | 6 |
| Total | | 3 | 40 | 15 | 2 | 60 |

**Time management * Grade/GPA Crosstabulation**

Count

| | | Grade/GPA | | | | Total |
|---|---|---|---|---|---|---|
| | | A | B | C | D | |
| Time management | Have enough time to study and rest | 1 | 4 | 0 | 0 | 5 |
| | Do not have enough time to study and rest | 0 | 20 | 9 | 2 | 31 |
| | Have enough time to study but do not have time to rest | 2 | 16 | 6 | 0 | 24 |
| Total | | 3 | 40 | 15 | 2 | 60 |

**Health Condition * Grade/GPA Crosstabulation**

Count

| | | Grade/GPA | | | | Total |
|---|---|---|---|---|---|---|
| | | A | B | C | D | |
| Health condition | Have a regular eating with enough nutrition | 0 | 3 | 0 | 0 | 3 |
| | Do not have a regular eating and do not have enough nutrition | 2 | 4 | 1 | 0 | 7 |
| | Have enough sleep | 0 | 1 | 0 | 0 | 1 |
| | Do not have enough sleep | 0 | 14 | 8 | 0 | 22 |
| | Feel stressful, sad, dizzy and tired | 1 | 18 | 5 | 2 | 26 |
| | Easily get sick (cold, fever, eyesight problem, etc.) | 0 | 0 | 1 | 0 | 1 |
| Total | | 3 | 40 | 15 | 2 | 60 |